# កាតរកាពរ៉ាង័ពុទ្ធសាសនិក

# ចំពូកទី ១

# ករណីយកិច្ចនៃពុទ្ធសាសនិក

## I

## អ្នកបួស

1. *អ្នកប្រាថ្នាចង់បានជាសាវ័ករបស់តថាគត ត្រូវតែតាំងចិត្តសច្ចាលះបង់ការទាក់ទងជាបន្ទាល់ជាមួយនឹងគ្រួសារ លះបង់ការរស់នៅក្នុងសង្គមលោកិយ លះបង់ការជំពាក់ចិត្តនឹងមាសប្រាក់សម្បត្តិទ្រព្យ។*

*អ្នកលះបង់គ្រប់ការទាក់ទងទាំងនេះ ដើម្បីរកព្រះធម៌ ហើយគ្មានទីជម្រកជាអចិន្ត្រៃយ៍សម្រាប់រូបកាយនិងវិញ្ញាណរបស់ខ្លួន នឹងបានជាសាវ័កមួយអង្គរបស់តថាគត ហើយបានឈ្មោះថា អ្នកបួសគ្មានលំនៅខ្ជាប់ខ្ជួន។*

*បុគ្គលណា ទោះបីដើរតាមដានជើងរបស់តថាគត ហើយស្លៀកស្បង់របស់តថាគតក៏ដោយ បើចិត្តរបស់គេនៅជាប់ជំពាក់នឹងចំណង់លោភលន់ បុគ្គលនោះនៅឆ្ងាយពីតថាគត។ បើ*

*បុគ្គលណា ស្លៀកពាក់ជាអ្នកបួស តែមិនទទួលយកសេចក្តីប្រៀនប្រដៅរបស់តថាគត បុគ្គលនោះមើលតថាគតមិនឃើញទេ។*

*បុគ្គលណាលះបង់ចោលគ្រប់ចំណង់លោភលន់ ហើយមានចិត្តបរិសុទ្ធស្ងប់ ទោះបីបុគ្គលនោះនៅឆ្ងាយ អំពីតថាគតរាប់រយយោជន៍ក៏ដោយ ក៏ហាក់ដូចជានៅបង្កើយនឹងតថាគតដែរ។ បើបុគ្គលណាទទួលយកព្រះធម៌ បុគ្គលនោះនឹងអាចមើលឃើញតថាគតតាមព្រះធម៌នោះឯង។*

2. *សាវ័ករបស់តថាគត ដែលជាអ្នកបួសឥតទីលំនៅជាខ្ជាប់ខ្ជួន ត្រូវតែប្រតិបត្តិវិន័យទាំងបួន ហើយយកវិន័យទាំងនោះជាគ្រឹះសម្រាប់ជីវិតរបស់ខ្លួន។*

*ទី១-ស្លៀកសម្លៀកបំពាក់ចាស់ ដែលគេបោះចោល។ ទី២ បានចំណីអាហារ ដោយសារការដើរបិណ្ឌបាត។ ទី៣ ជ្រកសំណាក់នៅក្រោមដើមឈើ ឬលើផ្ទាំងសិលា កាលណារាត្រីកាលមកដល់។ ទី៤ មើលថែជំងឺរបស់ខ្លួន តែនឹងថ្នាំពិសេសដែលផ្សំឡើងអំពីទឹកមូត្រនៃសត្វពាហនៈដែលអ្នកបួសដូចគ្នានាំយកមកឲ្យ។*

*ជីវិតជាអ្នកសុំទាន គឺកាន់បាត្រដើរសុំទានគេ ពីផ្ទះមួយ*

ទៅផ្ទះមួយៗ តែកិច្ចនេះមិនមែនត្រូវបាន អ្នកណាម្នាក់បង្ខំគេឡើយ ឬកាលៈទេសៈណាមួយ ឬសេចក្តីប្រាថ្នាលោកណាមួយរបស់គេ មកបង្ខំគេឲ្យធ្វើកិច្ចនេះ ក៏ទេដែរ។ គេធ្វើដោយឆន្ទៈល្អរបស់គេផ្ទាល់ ពីព្រោះគេយល់ថា ជីវិតក្នុងជំនឿជ្រះថ្លានាំឲ្យគេបានចៀសផុតពីភាពថ្លឹងថ្លែងនៃជីវិត នាំឲ្យគេបានចៀសផុតពីទុក្ខ ហើយនាំឲ្យគេបានទៅដល់ពន្លឺត្រាស់ដឹង។

ជីវិតអ្នកបួសឥតទីស្នាក់អាស្រ័យខ្ជាប់ខ្ជួន មិនមែនជាជីវិតស្រណុកស្រួលទេ។ គេមិនត្រូវប្រកបជីវិតនេះទេ បើគេមិនអាចរក្សាគ្រប់គ្រងចិត្តរបស់គេ ឲ្យបានរួចផុតពីចំណង់លោកលន់និងសេចក្តីខឹងក្រោធ បើគេមិនអាចត្រួតត្រាចិត្តនិងវិញ្ញាណទាំងប្រាំរបស់គេបាន។

3. ដើម្បីតាំងខ្លួនជាអ្នកបួសឥតទីលំនៅខ្ជាប់ខ្ជួន ហើយអាចឆ្លើយរួចថាខ្លួនជាអ្នកបួស គេត្រូវតែតាំងចិត្តសច្ចាថាៈ

«ខ្ញុំសច្ចាថានឹងបំពេញគ្រប់កិច្ចទាំងអស់ ដែលជាចាំបាច់សម្រាប់អ្នកបួស។ ខ្ញុំសច្ចាតាំងចិត្តស្មោះត្រង់ ខិតខំឲ្យបានទៅជាអ្នកបួសពិតប្រាកដមួយរូប។ ខ្ញុំនឹងដឹងគុណជនទាំងឡាយ

ដែលធ្វើទានដល់ខ្ញុំ ហើយខ្ញុំនឹងខំធ្វើឲ្យជនទាំងនោះបានប្រកប សេចក្តីសុខជាទីបំផុត ដោយសារអានិសង្សនៃជីវិតតឹងរឹងល្អ ប្រសើររបស់ខ្ញុំ»។

កិច្ចផ្សេងៗ ដែលអ្នកបួសឥតទីលំនៅខ្ជាប់ខ្ជួនត្រូវព្យាយាម ប្រតិបត្តិគឺៈ ត្រូវធាប់ចេះមានការអៀនខ្មាស ហើយធាប់ចាប់ អារម្មណ៍ដល់ការអាប់យស កាលណាបានប្រព្រឹត្តខុស។ ត្រូវ រក្សាកាយវាចា និងចិត្ត ឲ្យបានបរិសុទ្ធ ដើម្បីរស់ក្នុងជីវិតបរិ-សុទ្ធ។ ត្រូវប្រុងប្រយ័ត្នការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំ។ មិនត្រូវឡប់សតិ ដោយសារសេចក្តីសប្បាយ ដែលមិនឋិត ថេរ។ មិនត្រូវអួតខ្លួនឯង ហើយមើលងាយអ្នកឯទៀត។ មិន ត្រូវខ្ជិលច្រអូស ហើយដេកដំអក់យូរលង់។

ពេលល្ងាច ត្រូវអង្គុយភាវនាដោយស្ងៀមស្ងប់ មួយរយៈ វេលា រួចហើយចេញដើរបន្តិចមុននឹងចូលដេក។ ដើម្បីដេក ឲ្យបានសុខស្ងប់ ត្រូវដេកផ្អៀងទៅស្តាំ យកជើងផ្គុំគ្នា ហើយ គិតជាចុងក្រោយដល់ពេលដែលត្រូវភ្ញាក់ឲ្យបានរហ័សពីព្រឹក ព្រហាម។ នៅពេលព្រឹក ត្រូវមានពេលមួយរយៈទៀត ដើម្បី អង្គុយភាវនាដោយស្ងាត់ស្ងៀម រួចហើយចេញដើរបន្តិច។

ជារៀងរាល់ថ្ងៃ ត្រូវប្រុងប្រយ័ត្នរក្សាគ្រប់គ្រងចិត្តឲ្យបាន ត្រឹមត្រូវជានិច្ច។ ត្រូវរកកន្លែងស្ងប់ស្ងាត់អង្គុយភាវនាគិតរក្សា ការពារកាយ និងចិត្ត ទប់ទល់នឹងសេចក្តីលោភលន់សេចក្តី ក្រោធខឹង សេចក្តីល្ងង់ខ្លៅ សេចក្តីខ្ជិលច្រអូស សេចក្តីធ្វេស ប្រហែស សេចក្តីសោកស្តាយ ការមានមន្ទិលសង្ស័យ ហើយ និងចំណង់លោកិយឯទៀតទាំងអស់។

ព្រមដោយការសង្រួមចិត្តនេះ គេត្រូវបណ្តុះបណ្តាល គតិធម៌ប្រសើរបំផុតឲ្យចែងចាំឡើង ហើយប្រាថ្នាឆ្ពោះទៅរក ពន្លឺត្រាស់ដឹងពេញលេញតែមួយគត់។

4. អ្នកបួសណាភ្លេចខ្លួន រអិលធ្លាក់ទៅក្នុងចំណង់លោភលន់ បណ្តាលឲ្យសេចក្តីក្រោធខឹងចេញចូលបានតាមចិត្ត ចិញ្ចឹម ចិត្តចង់គំនុំ ចិត្តប្រណែននិន្ទា ចិត្តឡើងអំនួត ចិត្តឡឹត ចិត្ត លាក់ពុត គឺដូចជាកាន់ដាវមុខពីរ ដែលស្រោបដោយស្បៃ យ៉ាងស្តើងហៀ ដូច្នោះដែរ។

គ្រាន់តែស្លៀកស្បង់រហែករយ៉ីរយ៉ៃជាអ្នកបួស ហើយកាន់ បាត្រមួយនោះ មិនមែនជាអ្នកបួសទេ។ គ្រាន់តែបេះសូត្រធម៌

រុំលឥតទាក់នោះ មិនមែនជាអ្នកបួសទេ។ បុគ្គលទាំងនេះគឺបួសតែសម្បកក្រៅ តែប៉ុណ្ណោះ។

ទោះបីជាមានសភាពខាងក្រៅជាអ្នកបួសទុំះក៏ដោយតែ បើមិនអាចកំចាត់បង់នូវចំណង់លោកិយបានទេ មិនមែនជាអ្នកបួសទេ។ គឺដូចជាកូនក្មេងដែលស្លៀកស្បង់លោកសង្ឃតែប៉ុណ្ណោះ។

បុគ្គលដែលអាចហៅបានថា ជាអ្នកបួសពិតប្រាកដ គឺបុគ្គលដែលអាចសង្រួមគ្រប់គ្រងចិត្តរបស់ខ្លួនបាន បុគ្គលដែលមានគតិបណ្ឌិត បុគ្គលដែលចៀសផុតពីគ្រប់ចំណង់លោកិយ បុគ្គលដែលមានគោលបំណងតែមួយគត់ គឺការបានសម្រេចពន្លឺត្រាស់ដឹង។

អ្នកបួសពិតប្រាកដ សម្រេចចិត្តខំព្យាយាមឲ្យទាល់តែបានសម្រេចពន្លឺត្រាស់ដឹង ទោះបីគេត្រូវអស់តំណក់ឈាមជាទីចុងក្រោយរបស់គេក៏ដោយ ឬឆ្អឹងរបស់គេ ត្រូវខ្ទេចខ្ទីទៅជាផង់ធូលីក៏ដោយ។ អ្នកបួសដែលខំព្យាយាមយ៉ាងអស់សមត្ថភាពនឹងបានសម្រេចគោលបំណង ដែលជាប្រត្យក្សភាពនៃសមត្ថភាពរបស់ខ្លួន ក្នុងការបំពេញកុសលកិច្ចនៃអ្នកបួសដើរគ្រប់ទីកន្លែង ឥតកំណត់។

5. *បេសកកម្មរបស់អ្នកបួស គឺផ្សាយពន្លឺធម៌ទូន្មានរបស់ព្រះពុទ្ធ។ អ្នកបួសមានភារកិច្ចទេសនាពន្យល់ព្រះធម៌ដល់មហាជនទូទៅ ដាស់អ្នកដេកលក់ឲ្យក្រោក កែតម្រង់អ្នកយល់ខុស ជួយដាស់តឿនមហាជនឲ្យបានប្រកបនូវឧត្តមគតិ។ អ្នកបួសត្រូវចេញដើរសព្វទិសទី ដើម្បីទេសនាផ្សាយព្រះធម៌ឲ្យបានសាយសុស ទោះបីភារកិច្ចនេះ អាចនឹងបណ្តាលគ្រោះថ្នាក់ដល់ជីវិតដ៏ដោយ។*

*បេសកកម្មរបស់អ្នកបួស មិនមែនស្រួលទេ។ ហេតុនេះ អ្នកដែលប្រាថ្នាចង់បានជាអ្នកបួស ត្រូវតែស្លៀកស្បង់ព្រះពុទ្ធ អង្គុយលើអាសនៈព្រះពុទ្ធ ហើយចូលទៅក្នុងសំណាក់ព្រះពុទ្ធ។*

*ស្លៀកស្បង់ព្រះពុទ្ធគឺតាំងខ្លួនឲ្យរាបសា ខំព្យាយាមដោយទៀងទាត់។ អង្គុយលើអាសនៈព្រះពុទ្ធ គឺមើលឃើញវត្ថុទាំងឡាយអត់ខ្លឹមសារ ហើយគ្មានការជំពាក់ចិត្តទៅលើវត្ថុទាំងនោះ។ ចូលទៅក្នុងសំណាក់ព្រះពុទ្ធ គឺមានសេចក្តីករុណាមហាអាសូរចំពោះគ្រប់សត្វលោក។*

6. *អ្នកដែលប្រាថ្នាផ្សាយព្រះធម៌ឲ្យបានលទ្ធផល ត្រូវមានការ*

គិតប្រុងប្រយ័ត្នបួនគឺៈ ទី១ ត្រូវប្រយ័ត្នដំណើរឫកពាររបស់ខ្លួន ទី២ ត្រូវប្រយ័ត្នពាក្យសំដីនិយាយពន្យល់គេ ទី៣ត្រូវគិតពីគោលបំណងក្នុងការនិយាយពន្យល់គេ ទី៤ត្រូវគិតទៅដល់សេចក្តីករុណាមហាអាសូរ។

ដើម្បីបានជាគ្រូអាចារ្យបង្រៀនព្រះធម៌ អ្នកបួសត្រូវតែៈ ទី១ មានសេចក្តីព្យាយាមទៀងទាត់ មានសភាពរម្យទម មិនឈ្លើយឬចង់បានមុខមាត់ គិតជានិច្ចដល់ភាពទទេឥតខ្លឹមសារនៃវត្ថុទាំងអស់ ហើយមិនជាប់ជំពាក់ចិត្តនឹងវត្ថុអ្វីមួយឡើយ។ ការចេះគិតប្រុងប្រយ័ត្នរបៀបនេះ អាចឲ្យបានប្រកបចរិយាមារយាទត្រឹមត្រូវ។

ទី២ ត្រូវមានការប្រុងប្រយ័ត្ន កាលណាចូលទៅក្នុងសង្គមមនុស្សផ្សេងៗ។ ត្រូវចៀសវាងមនុស្ស ដែលប្រកបជីវិតកាចសាហាវ ឬប្រកាន់អំណាច។ ត្រូវចៀសវាងកុំចូលជិតស្រី។ ត្រូវទុកមនុស្សគ្រប់ប្រភេទជាមិត្ត ដោយនឹកគិតជានិច្ចថា អ្វីៗទាំងអស់ សុទ្ធតែជាការប្រមូលបញ្ចូលគ្នាមកអំពីហេតុ និងល័ក្ខ-ខ័ណ្ឌ។ ដោយហេតុនេះ មិនត្រូវបន្ទោសបុគ្គល មិនត្រូវជេរបុគ្គល មិនត្រូវទិទៀនបុគ្គល ឬហែកកេរ្តិ៍បុគ្គលទេ។

ទី៣ ត្រូវរក្សាចិត្តរបស់ខ្លួនឲ្យបានស្ងប់ ដោយទុកព្រះពុទ្ធជាបិតានៃសាសនា ទុកអ្នកបួសឯទៀត ដែលមានជម្រុលទៅមុខក្នុងការព្យាយាមដើម្បីសម្រេចពន្លឺត្រាស់ដឹង ជាគ្រូអាចារ្យ ហើយយកចិត្តទុកដាក់នឹងមនុស្សគ្រប់ប្រភេទ ដោយចិត្តមានមេត្តាអាសូរ។ ដូច្នេះ អ្នកបួសត្រូវប្រៀនប្រដៅមនុស្សលោកគ្រប់ប្រភេទ ឲ្យបានស្មើៗគ្នា។

ទី៤ ត្រូវបញ្ចេញចិត្តមេត្តាអាសូររបស់ខ្លួន ឲ្យបានធំបំផុតដូចព្រះពុទ្ធ។ ត្រូវមានសេចក្តីប្រាថ្នាមោះមុត ចង់ឲ្យអ្នកដែលមិនស្គាល់ផ្លូវទៅកាន់ពន្លឺត្រាស់ដឹង បានស្តាប់ហើយប្រតិបត្តិតាមធម៌ព្រះពុទ្ធ។ ត្រូវប្រសិទ្ធិពរឲ្យអ្នកទាំងនោះបានសម្រេចពន្លឺត្រាស់ដឹង ហើយខំបំពេញបំណងអ្នកទាំងនោះដោយមិនគិតដល់ប្រយោជន៍ផ្ទាល់ខ្លួន។

II

# អ្នកជាគ្រហស្ថ

1. ដូចបានស្តីពីលើមកហើយ ដើម្បីនឹងបានជាសាវ័ករបស់ព្រះពុទ្ធ គេត្រូវតែជឿលើរតនៈទាំងបី គឺព្រះពុទ្ធ ព្រះធម៌

ព្រះសង្ឃ។

ដើម្បីបានជាពុទ្ធសាសនិកមួយរូប ត្រូវមានជំនឿជ្រះថ្លាលើព្រះពុទ្ធ ជឿតាមសេចក្តីទូន្មានរបស់ព្រះអង្គ ហាត់រៀននិងប្រតិបត្តិតាមសេចក្តីទូន្មាននោះ ហើយបណ្តុះពង្រីកពុទ្ធិកសហគមន៍។

ពុទ្ធសាសនិក ត្រូវប្រតិបត្តិវិន័យប្រាំគឺៈ មិនសម្លាប់ មិនលួចប្លន់ មិនប្រព្រឹត្តអំពើផិតក្បត់ មិនភូតភរបោកប្រាស់ មិនសេពគ្រឿងស្រវឹង។

ពុទ្ធសាសនិក មិនត្រឹមតែជឿលើរតនៈទាំងបី ប្រតិបត្តិតាមវិន័យទាំងប្រាំ សម្រាប់តែខ្លួនឯងម្នាក់នោះទេ ក្នុងករណីដែលអាចធ្វើបាន គេត្រូវតែចែករំលែកជំនឿនិងកិច្ចប្រតិបត្តិទាំងនោះដល់អ្នកដទៃឯទៀតផង ជាពិសេសដល់មាតាបិតាមិត្តភក្តិ ដោយខិតខំក្រើនរំលឹកអ្នកទាំងនោះ ឲ្យមានជំនឿជ្រះថ្លាលើព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃ ដើម្បីឲ្យអ្នកទាំងនោះអាចបានរួមទទួលសេចក្តីមហាករុណាអាសូររបស់ព្រះពុទ្ធជាមួយផង។

ពុទ្ធសាសនិក ត្រូវនឹកគិតជានិច្ចថា វិចារណញ្ញាណដែល

នាំឲ្យខ្លួនមានជំនឿលើរតនៈទាំងបី ហើយប្រតិបត្តិតាមវិន័យទាំងប្រាំគឺ ការអាចនឹងបានសម្រេចពន្លឺត្រាស់ដឹងនៅទីបំផុត។ ហេតុនេះ ទោះបីជារស់នៅក្នុងពិភពដែលពោរពេញទៅដោយចំណង់យ៉ាងនេះក៏ដោយ គេត្រូវតែចៀសវាងកុំបីមានការជាប់ជំពាក់ចិត្ត។

ពុទ្ធសាសនិក ត្រូវគិតជានិច្ចថា យូរឬឆាប់ គេនឹងត្រូវបែកឃ្លាតពីឪពុកម្ដាយគ្រួសារបងប្អូន។ ហេតុនេះ គេមិនត្រូវជាប់ជំពាក់ចិត្តនឹងវត្ថុទាំងឡាយក្នុងជីវិតនេះទេ តែត្រូវបែរចិត្តទៅរកពិភពពន្លឺត្រាស់ដឹង ដែលគ្មានអ្វីត្រូវបានវិនាសបាត់ជាដាច់ខាត។

2. អ្នកដែលស្ដាប់ហើយមានជំនឿជ្រះថ្លាមុតមាំ លើសេចក្ដីទូន្មានរបស់ព្រះពុទ្ធ សេចក្ដីសុខស្ងប់នឹងកើតមានឡើងជាប្រត្យក្សនៅក្នុងចិត្តរបស់គេ សេចក្ដីស្ងប់ដែលជះចេញជាពន្លឺរស្មីទៅគ្រប់អន្ទើ ហើយចាំងត្រឡប់មករកខ្លួនគេវិញ។

ចិត្តមានជំនឿជ្រះថ្លាមុតមាំ ជាចិត្តបរិសុទ្ធ ស្ងប់ មានសេចក្ដីអំណត់និងសេចក្ដីក្លាហានជានិច្ច។ ជាចិត្តមិនសន្សំជម្ងោះ

មិនបណ្តាលទុក្ខទោសដល់អ្នកផងទាំងពួង។ តែផ្ទុយទៅវិញ ជាចិត្តបេះនឹកគិតដល់ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ យ៉ាង នេះ សេចក្តីសុខស្ងប់នឹងកើតមានឡើងដោយឯកឯងនៅក្នុង ចិត្តដ៏ប្រសើរនោះ ហើយរស្មីនៃពន្លឺត្រាស់ដឹងនឹងត្រូវបាន មើលឃើញនៅសព្វទិសទី។

ដោយសារជំនឿជ្រះថ្លាមុតមាំនេះ ពុទ្ធសាសនិកទាំងឡាយ អាចបានស្ថិតនៅជិតព្រះពុទ្ធ អាចបានចាកផុតពីអត្តទត្តភាព ពីការជាប់ជំពាក់ចិត្តនឹងទ្រព្យសម្បត្តិ។ ដូច្នេះ គេមិនភ័យខ្លាច នឹងជីវិតសព្វថ្ងៃ មិនព្រួយបារម្ភនឹងការនិន្ទាឈ្នានីស។

ដោយគេជឿជាក់ថានឹងបានទៅកើត នៅក្នុងដែនដីព្រះ ពុទ្ធ គេលែងភ័យខ្លាចសេចក្តីស្លាប់។ ដោយគេជឿលើសេចក្តី ពិត និងសន្តិភាពនៃពុទ្ធសាសនា គេអាចលាតត្រដាងជំនឿ ជ្រះថ្លារបស់គេនៅមុខប្រជុំជន ដោយសេរី ដោយមិនខ្លាច ញញើត។

ដោយចិត្តរបស់គេបានពោរពេញទៅដោយសេចក្តីមេត្តា អាសូរចំពោះមនុស្សទូទៅ គេមិនធ្វើការរើសញែកស្រឡាញ់ អ្នកនេះស្អប់អ្នកនោះឡើយ។ ផ្ទុយទៅវិញគេទុកបុគ្គលទាំង

ឡាយក្នុងភាពស្មើគ្នា។ ដោយចិត្តគេបានរួចផុតពីការស្រឡាញ់និងការស្អប់ គេនឹងអាចបំពេញអំពើជាកុសលដោយសុចិភាពសមភាព និងក្តីសប្បាយរីករាយ។

ទោះបីគេរស់នៅក្នុងភាពក្ររហេមរហាមក៏ដោយ ឬក្នុងភាពមានស្តុកស្តម្ភក៏ដោយ ការបណ្តុះបណ្តាលជំនឿជ្រះថ្លាមុតមាំរបស់គេនៅតែចម្រើនទៅមុខជានិច្ច។ គេគោរពប្រណិ-ប័តន៍សេចក្តីទូន្មានរបស់ព្រះពុទ្ធជានិច្ច។ ពាក្យសច្ចានិងការប្រព្រឹត្តិរបស់គេត្រូវបានសមហេតុផល ស្របគ្នាជានិច្ច។ គេយកគតិធម៌ ជាយានសម្រាប់ដឹកនាំគេ។ ចិត្តរបស់គេនឹងនមាំដូចភ្នំគេប្រាថ្នាតែម្យ៉ាងគត់ គឺខំដើរទៅមុខតាមគន្លងនៃពន្លឺត្រាស់ដឹង។

ទោះបីគេត្រូវបានបង្ខំឲ្យរស់ក្នុងស្ថានភាពដ៏ពិបាក នៅក្នុងចំណោមមនុស្សពាលក៏ដោយ ដោយគេមានជំនឿជ្រះថ្លាលើព្រះពុទ្ធ ចិត្តរបស់គេជាចិត្តព្រះពុទ្ធគេនឹងខំពន្យល់ណែនាំជនពាលទាំងនោះឲ្យដើរតាមគន្លងធម៌ ឲ្យទាល់តែបាន។

3. ដូច្នេះ កិច្ចសំខាន់ជាងគេបង្អស់ គឺការប្រាថ្នាចង់ស្តាប់

ប្រតិបត្តិតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធ។

បើមានគេទូន្មានយើងថា ឲ្យដើរឆ្លងកាត់ភ្លើងដើម្បីទៅដល់ពន្លឺត្រាស់ដឹង យើងត្រូវតែមានបំណងនឹងដើរឆ្លងកាត់ភ្លើងនោះ។

ក្នុងលោកដែលមានភ្លើងឆេះសន្ធោសន្ធៅនេះ ការបានស្តាប់ឮព្រះនាមព្រះពុទ្ធ ជាការបានទទួលការស្រោចស្រង់ដ៏ជាទីពេញចិត្ត។

អ្នកដែលប្រាថ្នាស្តាប់ ប្រតិបត្តិតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធ មិនត្រូវមានអត្តទត្តភាពគិតតែពីខ្លួនឯងនោះទេ ត្រូវមានចិត្តបុណ្យចំពោះមនុស្សទូទៅ ក្នុងភាពស្មើៗគ្នា។ គេត្រូវគោរពបុគ្គលដែលគួរគោរព ត្រូវបម្រើបុគ្គលដែលគួរបម្រើ ត្រូវទុកបុគ្គលទូទៅក្នុងភាពជាទីស្រឡាញ់ពេញចិត្តស្មើៗគ្នា គឺមិនស្រឡាញ់អ្នកនេះជាងអ្នកនោះ។

គឺតាមរបៀបនេះហើយ ដែលពុទ្ធសាសនិកទាំងឡាយត្រូវចាប់ផ្តើមហាត់បំពត់ចិត្តរបស់ខ្លួន កុំឲ្យមានការសៅហ្មងដោយសារអំពើផ្សេងៗរបស់អ្នកដទៃ។ គឺតាមរបៀបនេះហើយដែលគេទទួលសេចក្តីទូន្មានរបស់ព្រះពុទ្ធ យកមកប្រតិបត្តិ

តាមដោយគ្មានប្រាថ្នាអាក្រក់លើអ្នកឯទៀត ដោយមិនរវល់ នឹងពាក្យនិន្ទាពីអ្នកឯទៀត ដោយមិនគិតបែកបែររេទៅរកផ្លូវផ្សេងទៀត។

អ្នកដែលមិនជឿព្រះពុទ្ធ មើលឃើញជិត គិតតែពីខ្លួនឯងផ្ទាល់ ជាហេតុបណ្ដាលឲ្យចិត្តរបស់គេឡើងជាចង្អៀតចង្អល់ មានមន្ទិលសៅហ្មង។ អ្នកដែលជឿព្រះពុទ្ធ ជឿយ៉ាងមុតមាំលើព្រហ្មវិហារធម៌របស់ព្រះពុទ្ធ ដែលគ្របដណ្ដប់សត្វលោកទូទៅ ជាហេតុបណ្ដាលឲ្យចិត្តរបស់គេបានទូលាយ អស់មន្ទិលសៅហ្មង។

4. អ្នកដែលបានស្ដាប់ឮហើយទទួលយកសេចក្ដីទូន្មានរបស់ព្រះពុទ្ធ ដឹងថាជីវិតរបស់គេមិនឋិតថេរ រូបកាយរបស់គេជាការប្រមូលផ្ដុំនៃទុក្ខ ជាប្រភពនៃកម្មអាក្រក់។ ហេតុនេះ គេអស់មានចិត្តជាប់ជំពាក់នឹងរូបកាយនោះ។

តែនៅពេលជាមួយគ្នានោះ គេមិនត្រូវធ្វេសប្រហែសក្នុងការថែរក្សារូបកាយរបស់គេឡើយ។ គេថែរក្សារូបកាយរបស់គេ មិនមែនក្នុងបំណងបំពេញចំណង់រូបកាយនោះទេ តែដោយសាររូបកាយ ជារបស់ចាំបាច់សម្រាប់ការបានសម្រេច

គតិធម៌ ចាំបាច់សម្រាប់ការបំពេញបេសកកម្មពន្យល់ផ្លូវដល់អ្នកឯទៀត។

បើគេមិនថែរក្សារូបកាយរបស់គេ គេមិនអាចរស់បានយូរទេ។ បើគេរស់មិនបានយូរ គេមិនអាចធ្វើវត្តប្រតិបត្តិពុទ្ធសាសនាឲ្យបានល្អិតល្អន់ទេ គេមិនអាចផ្សាយសាសនានេះឲ្យបានសុសសព្វទេ។

អ្នកដែលប្រុងធ្វងស្មឹង គេមើលថែរក្សាក្បូនចម្ងរបស់គេ។ អ្នកដែលប្រុងធ្វើដំណើរផ្លូវឆ្ងាយ គេមើលថែទាំសេះរបស់គេ។ ដូចគ្នានេះ អ្នកដែលប្រាថ្នាឲ្យបានសម្រេចពន្លឺត្រាស់ដឹង គេមើលថែទាំរូបកាយរបស់គេ។

ពុទ្ធសាសនិកទាំងឡាយស្លៀកសម្លៀកបំពាក់ ដើម្បីការពារដំណើរផ្លាស់ប្តូរនៃធាតុអាកាសត្រជាក់ក្តៅ ដើម្បីបិទបាំងកេរខ្មាស មិនមែនដើម្បីលំអរូបកាយទេ។

គេបរិភោគចំណីអាហារសម្រាប់ទ្រទ្រង់រូបកាយ ដើម្បីនឹងបាន ស្តាប់ឮហើយទទួលយកសេចក្តីទូន្មានរបស់ព្រះពុទ្ធ ហើយពន្យល់ប្រាប់បន្តទៅអ្នកឯទៀត មិនមែនសម្រាប់ការត្រេកត្រអាលទេ។

គេដេកពួនក្នុងផ្ទះក៏ដូច្នោះដែរ គឺដើម្បីការពាររូបកាយរបស់គេ ទប់ទល់នឹងការលុកលុយនៃតណ្ហាលោកិយ ហើយនិងព្យុះសង្ឃរានៃសេចក្តីទូន្មានអាក្រក់របស់ទមិឡអន្យតិរ្ថិយ៍។ ហេតុនេះ គេត្រូវប្រើប្រាស់ផ្ទះក្នុងគោលបំណងត្រឹមត្រូវពិតប្រាកដ មិនមែនដើម្បីបង្អួតគេ ឬដើម្បីលាក់អំពើអត្តទត្ថរបស់ខ្លួនទេ។

ដូច្នេះ គេត្រូវចេះថ្លឹងតម្លៃនៃវត្ថុទាំងឡាយ ហើយប្រើប្រាស់វាតែនៅក្នុងគោលបំណងសម្រាប់ពន្លឺត្រាស់ដឹង ហើយនឹងសេចក្តីទូន្មានរបស់ព្រះពុទ្ធ។ គេមិនត្រូវជាប់ជំពាក់នឹងវត្ថុទាំងនោះ ដោយសារតែមានចិត្តអត្តទត្ថនោះឡើយ តែគេត្រូវប្រើប្រាស់របស់អស់នោះជាយាន ដើម្បីបញ្ជូនសេចក្តីទូន្មានរបស់ព្រះពុទ្ធទៅអ្នកឯទៀត។

ដូច្នេះ គេត្រូវមានចិត្តគិតដល់សេចក្តីទូន្មានរបស់ព្រះពុទ្ធជានិច្ច ទោះបីគេរស់នៅជាមួយនឹងគ្រួសារក៏ដោយ។ គេត្រូវចេះគ្រប់គ្រងរក្សាគ្រួសាររបស់គេ ដោយគតិធម៌ និងសេចក្តីស្រឡាញ់ថ្នាក់ថ្នម ហើយរកគ្រប់មធ្យោបាយ ដើម្បីក្រើនរំលឹកសមាជិកទាំងអស់នៃគ្រួសារ ឲ្យបានកើតមានជំនឿជ្រះថ្លាលើពុទ្ធឱវាទ។

5. ពុទ្ធសាសនិកទាំងឡាយ ជារៀងរាល់ថ្ងៃត្រូវគិតដល់កិច្ចដូចតទៅនេះ ៖ តើត្រូវគោរពបម្រើមាតាបិតារបៀបណា? តើត្រូវទំនុកបម្រុងក្រុមគ្រួសាររបៀបណា? តើត្រូវគ្រប់គ្រងខ្លួនឯងរបៀបណា? តើត្រូវគោរពធ្វើតាមព្រះពុទ្ធរបៀបណា?។

ដើម្បីគោរពបម្រើមាតាបិតាឲ្យបានគាប់ប្រសើរ គេត្រូវរៀនឲ្យចេះមានមេត្តាធម៌ដល់សត្វមានជីវិតទាំងអស់។ ដើម្បីរស់នៅជាមួយប្រពន្ធកូនឲ្យបានសុខសប្បាយ គេត្រូវចេះលះបង់គ្រប់ចំណង់ និងគំនិតចង់បានសុខស្រួលផ្ទាល់ខ្លួន។

ក្នុងពេលបានស្ដាប់ឮតន្ត្រីពីរោះនៃជីវិតគ្រួសារ គេមិនត្រូវភ្លេចនឹកដល់តន្ត្រីនៃពុទ្ធសាសនា ដែលរឹតតែស្រទន់ពីរោះជាងនេះទៅទៀត។ ក្នុងពេលបានរស់នៅដោយសុខសាន្តក្នុងជម្រកផ្ទះសម្បែង គេត្រូវគិតជារឿយៗ ដល់ជម្រកនៃពុទ្ធសាសនា ដែលរឹតតែបានសុខជាងនេះទៅទៀត ដែលសន្តបុគ្គលទាំងឡាយ យកជាទីជ្រកពួនការពារសេចក្ដីសៅហ្មងហើយនិងសេចក្ដីទុក្ខ។

ពុទ្ធសាសនិកទាំងឡាយ កាលណាធ្វើទាន ត្រូវធ្វើដោយ

ស្មោះ ត្រូវកំចាត់សេចក្ដីប្រាថ្នាលោភលន់ឲ្យអស់ពីក្នុងចិត្ត។ កាលណា គេនៅកណ្ដាលចំណោមមនុស្សគ្រប់ប្រភេទ ចិត្តរបស់គេត្រូវនៅជាមួយនឹងសន្តបុគ្គល។ កាលណាគេជួបប្រទះទុក្ខព្រួយ គេត្រូវរក្សាចិត្តឲ្យស្ងប់ ឲ្យរួចផុតពីឧបសគ្គ។

កាលណាគេជ្រកកោននឹងព្រះពុទ្ធ គេត្រូវប្រាថ្នារកប្រាជ្ញាញាណរបស់ព្រះអង្គ។

កាលណាគេជ្រកកោននឹងព្រះធម៌ គេត្រូវប្រាថ្នារកឲ្យយល់សេចក្ដីពិត ដែលធំធេងដូចមហាសមុទ្រប្រាជ្ញាញាណរបស់ព្រះពុទ្ធ។

កាលណាគេជ្រកកោននឹងព្រះសង្ឃ គេត្រូវប្រាថ្នាចែករំលែកសេចក្ដីសុខស្ងប់រវាងគ្នានឹងគ្នា ដោយមិនគិតដល់ប្រយោជន៍សម្រាប់តែខ្លួនឯងម្នាក់។

កាលណាគេស្លៀកពាក់ គេមិនត្រូវភ្លេចសំលៀកបំពាក់ជាកុសល និងជាអំពើពបទាប យកមកស្លៀកពាក់ផងទេ។

កាលណាគេបន្ទោបង់លាមក គេត្រូវប្រាថ្នាឲ្យសេចក្ដីលោភលន់ សេចក្ដីខឹងក្រោធ សេចក្ដីយល់ប្រឡំ បានចេញអស់អំពីចិត្តរបស់គេ។

*កាលណាគេប្រឹងឡើងផ្លូវចោត គេត្រូវទុកផ្លូវ នោះជាផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ដែលនាំគេឲ្យបានរួចផុតពីពិភពពោរពេញទៅដោយការបំភាន់ភ្នែក។ កាលណាគេដើរតាមផ្លូវស្រណុកស្រួល គេត្រូវធ្មៀតយកសេចក្ដីស្រណុកស្រួលនេះជាជម្រុលដើម្បីឆាប់បានទៅដល់សភាពព្រះពុទ្ធ។*

*កាលណាគេឃើញស្ពាន គេត្រូវប្រាថ្នាបង្កើតស្ពានព្រះពុទ្ធសាសនា ដើម្បីឲ្យមហាជនឆ្លង។*

*កាលណា គេជួបប្រទះនឹងមនុស្សមានទុក្ខវេទនា គេត្រូវមានចិត្តសង្វេគដល់ពិភពលោក ដែលប្រែប្រួលមិនចេះឈប់ឈរនេះ។*

*កាលណា គេជួបប្រទះនឹងមនុស្សមានសេចក្ដីលោភលន់ពេញខ្លួន គេត្រូវប្រាថ្នាយ៉ាងមុតមាំរំដោះខ្លួនគេឲ្យរួចផុតអំពីការបំភាន់ភ្នែកនៃជីវិតលោកិយនេះ ហើយប្រាថ្នាឲ្យបានសម្រេចសម្បត្តិពិតប្រាកដគឺពន្លឺត្រាស់ដឹង។*

*កាលណាគេឃើញចំណីឈ្ងុយឆ្ងាញ់ គេត្រូវមានការប្រុងប្រយ័ត្ន។ កាលណាគេឃើញចំណីមិនឆ្ងាញ់ គេត្រូវប្រាថ្នាកុំឲ្យសេចក្ដីលោភឃ្លានកើតមានដល់គេទៀត។*

នៅពេលក្តៅខ្លាំងនារដូវក្តៅ គេត្រូវប្រាថ្នាឲ្យបានរួចផុតពីក្អក់ភ្លើងនៃតណ្ហាលោកិយ ហើយប្រាថ្នាឲ្យបានទទួលភាពត្រជាក់ស្រួលនៃពន្លឺត្រាស់ដឹង។ នៅពេលរងាខ្លាំងនារដូវត្រជាក់ គេត្រូវប្រាថ្នាឲ្យបានទទួលនូវកំដៅឃ្លុំស្រួលនៃព្រហ្មវិហាធម៌របស់ព្រះពុទ្ធ។

កាលណាគេសូត្រគម្ពីរព្រះធម៌ គេត្រូវតាំងចិត្តថាមិនបំភ្លេច ហើយប្រតិបត្តិតាមព្រះធម៌នោះ។

កាលណាគេគិតដល់ព្រះពុទ្ធ គេត្រូវប្រាថ្នាយ៉ាងមុតមាំឲ្យភ្នែករបស់គេបានភ្លឺដូចព្រះពុទ្ធ។

កាលណាគេដេកនាពេលយប់ គេត្រូវប្រាថ្នាឲ្យអង្គកាយវាចា និងចិត្តរបស់គេ បានត្រជាក់បរិសុទ្ធល្អ។ កាលណាគេក្រោកឡើងនាពេលព្រឹកព្រហាម គេត្រូវប្រាថ្នា ជាដំបូងបង្អស់ឲ្យចិត្តរបស់គេបានភ្លឺថ្លាពេញមួយថ្ងៃ ដើម្បីបានយល់ជាក់ច្បាស់នូវវត្ថុទាំងពួង។

6. អ្នកដែលជឿតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធដោយគេយល់ថាអ្វីៗទាំងអស់សុទ្ធតែអត់ខ្លឹមសារ ដូច្នេះគេមិនគិតងាយចំពោះ

វត្ថុទាំងអស់ដែលទាក់ទងនឹងជីវិតមនុស្សលោក។ ផ្ទុយទៅវិញ គេទទួលយកវត្ថុទាំងនោះតាមសភាពរបស់វា ហើយគេខិតខំធ្វើវាឲ្យទៅជាគ្រឿងឧបករណ៍ សម្រាប់ទៅកាន់ពន្លឺត្រាស់ដឹង។

គេមិនត្រូវគិតថាពិភពមនុស្សលោកនេះឥតន័យ ពោរពេញទៅដោយសេចក្តីស្មុកស្មាញច្របូកច្របល់ ហើយគិតស្រមៃថា ពិភពពន្លឺត្រាស់ដឹងពោរពេញទៅដោយអត្ថរស ហើយនិងសេចក្តីសុខសាន្ត។ ផ្ទុយទៅវិញគេត្រូវសម្ងឹងគិតទៅផ្លូវពន្លឺត្រាស់ដឹងតាមដោយរឿងទាំងអស់ដែលកើតមានឡើងនៅក្នុងលោកនេះ។

អ្នកដែលក្រឡេកមើលពិភពលោក ដោយភ្នែកល្អក់ស្រវាំងដោយសារសេចក្តីល្ងង់ខ្លៅ នឹងឃើញពិភពលោកនេះប្រកបទៅដោយកំហុស។ ប៉ុន្តែបើគេក្រឡេកមើលពិភពលោកនេះ តាមដោយប្រាជ្ញាភ្លឺថ្លា គេនឹងឃើញពិភពលោកដូចជាពិភពនៃពន្លឺត្រាស់ដឹងតែម្តង។

តាមពិត មានពិភពតែមួយគត់ គ្មានពីរទេ។ គ្មានពិភពមួយឥតន័យ ហើយពិភពមួយទៀតពោរពេញទៅដោយន័យ

នោះទេ។ គ្មានពិភពមួយល្អ ហើយពិភពមួយទៀតអាក្រក់នោះទេ។ គឺដោយសារតែគំនិតវែកញែករបស់មនុស្សលោកដែលនាំឲ្យគេគិតជានិច្ចថា មានពិភពពីរ។

បើគេអាចលះបង់គំនិតវែកញែកនេះបាន ហើយរក្សាចិត្តឲ្យបានបរិសុទ្ធតាមដោយពន្លឺសតិប្រាជ្ញា នោះគេនឹងឃើញថា មានពិភពតែមួយគត់ ដែលនៅក្នុងនោះអ្វីៗទាំងអស់សុទ្ធតែមានន័យ។

7. អ្នកដែលជឿតាមព្រះពុទ្ធ នឹងបានយល់អំពីភាពបរិសុទ្ធជាសកលតែមួយគ្មានពីរនៃវត្ថុទាំងឡាយ នៅក្នុងលោកនេះ។ ហេតុនេះ គេមានចិត្តប្រកបដោយមេត្តាធម៌ចំពោះមនុស្សទូទៅ ហើយមានចរិយារាបទាបក្នុងការជួយសង្គ្រោះអ្នកផងទាំងពួង។

ដូច្នេះ អ្នកជឿតាមព្រះពុទ្ធ មិនត្រូវមានចិត្តឡឹតប្រកបដោយអភិមានះទេ ត្រូវរក្សាចិត្តរាបទាប ចេះគួរសម ចេះជួយធុរៈអ្នកឯទៀត។ ចិត្តរបស់គេត្រូវតែឲ្យបានដូចជាដីមានជីជាតិដែលទទួលចិញ្ចឹមគ្រប់រុក្ខជាតិ ដោយគ្មានលំអៀងទៅខាង

ណាៗ ចិត្តដែលចេះជួយធុរៈអ្នកឯទៀត ដោយគ្មានការត្អូញត្អែរ ចិត្តដែលចេះស៊ូទ្រាំដោយក្ដីអំណត់ ចិត្តដែលត្រង់ទៀងទាត់ជានិច្ច ចិត្តដែលមានសេចក្ដីរីករាយជាទីបំផុត ក្នុងការជួយសង្គ្រោះជនកំសត់ទុរគត ហើយបណ្ដុះគ្រាប់ពូជនៃសេចក្ដីទូន្មានរបស់ព្រះពុទ្ធនៅក្នុងសន្ដានចិត្តរបស់អ្នកទាំងនោះ។

ចិត្តដែលប្រកបដោយសេចក្ដីអាសូរ ចេះមានមេត្តាធម៌ចំពោះជនកំសត់ទុរគត ទុកដូចជាមាតានៃមនុស្សលោកទាំងអស់ គឺចិត្តចេះគោរពមនុស្សទូទៅ ទុកមនុស្សទូទៅជាមិត្តចេះគោរពមនុស្សទូទៅទុកដូចជាឪពុកម្ដាយរបស់ខ្លួន។

ដូច្នេះ ទោះបីជាមានមនុស្សរាប់ម៉ឺននាក់ស្អប់អ្នកកាន់សាសនាព្រះពុទ្ធ ហើយមានបំណងអាក្រក់មកលើពុទ្ធបរិស័ទទាំងនោះក៏ដោយ ក៏មិនអាចបណ្ដាលទុក្ខទោសដល់អ្នកទាំងនោះបានឡើយ ព្រោះទុក្ខទោសទាំងនោះដូចជាពិសពុលមួយតំណក់តូច ដែលធ្លាក់ទៅក្នុងមហាសមុទ្រដូច្នោះដែរ។

8. ពុទ្ធសាសនិកទាំងឡាយ នឹងបានត្រេកអរសជាតិនៃសុកមង្គល ដោយសារទម្លាប់ចេះនឹកគិតដឹងគុណដល់ព្រះពុទ្ធ។

គេនឹងបានយល់ច្បាស់ថា ជំនឿមុតមាំរបស់គេគឺសេចក្ដីករុណាអាសូររបស់ព្រះពុទ្ធតែម្ដង ហើយជាអំណោយដែលព្រះពុទ្ធប្រទានមក។

ភក់ជ្រាំនៃតណ្ហាលោកិយ មិនអាចបង្កើតគ្រាប់ពូជនៃជំនឿមុតមាំបានទេ។ ប៉ុន្តែគឺដោយសារសេចក្ដីករុណាអាសូររបស់ព្រះពុទ្ធ ដែលគ្រាប់ពូជនៃជំនឿមុតមាំនោះ អាចកើតមាននៅក្នុងភក់ជ្រាំនៃតណ្ហាលោកិយនោះបាន។ ហើយទីបំផុត គ្រាប់ពូជនៃជំនឿមុតមាំនោះបណ្ដាលឲ្យចិត្តបានបរិសុទ្ធរហូតដល់មានជំនឿលើព្រះពុទ្ធ។

ដើមច័ន្ទន៍ ដែលមានក្លិនក្រអូប មិនអាចដុះក្នុងព្រៃឥរន្ធបានទេ។ យ៉ាងណាមិញ គ្រាប់ពូជនៃជំនឿលើព្រះពុទ្ធមិនអាចស្ថិតមាននៅក្នុងពិភព ពេញដោយសេចក្ដីភាន់ច្រឡំនោះបានទេ។

តែពេលនេះ ផ្កានៃជំនឿជ្រះថ្លាបានរីកនៅក្នុងទីភក់ជ្រាំនោះដោយពិតៗ។ ចំពោះរឿងនេះ យើងត្រូវសន្និដ្ឋានថា ផ្ការីកនៅកណ្ដាលពិភពភាន់ច្រឡំក៏ពិតមែនហើយ តែឫសរបស់វាស្ថិតនៅកន្លែងផ្សេងទៀតទេ ពោលគឺនៅក្នុងចិត្តរបស់ព្រះពុទ្ធនោះឯង។

ពុទ្ធសាសនិកណាបណ្ដោយឲ្យមានចិត្តជាអាត្មាអញ គេនឹងមានចិត្តប្រណៃនន្និទ្ធា លោភលន់ កាចសាហាវជាមិនខាន ពីព្រោះ ចិត្តរបស់គេនឹងពោរពេញទៅដោយសេចក្ដីលោភលន់ សេចក្ដីខឹងក្រោធ សេចក្ដីឡប់តក្កួតលេលា។ ប៉ុន្តែបើគេបែរទៅរកព្រះពុទ្ធ គឺគេបំពេញកិច្ចធំៗរបស់ព្រះពុទ្ធ ដូចបានរៀបរាប់ពីខាងលើមកហើយ។ តាមពិត កិច្ចទាំងនេះវាហួសពីការអាចបរិយាយបានទៅទៀត។

III

# របៀបរស់នៅដោយត្រឹមត្រូវ

1. ការគិតស្មានថា ទុក្ខទាំងឡាយមកពីទិសខាងកើត ឬទិសខាងលិច ជាការយល់ខុសស្រឡះ។ ទុក្ខទាំងឡាយ កើតមាននៅក្នុងចិត្តរបស់យើងផ្ទាល់តែម្តង។ ហេតុនេះ ជាការឆ្កួតសោះ ដែលខំការពារខ្លួនទប់ទល់នឹងទុក្ខ មកពីខាងក្រៅ ហើយមិនគិតគ្រប់គ្រងចិត្តរបស់ខ្លួនឯងផ្ទាល់។

មានទម្លាប់ពីបុរាណកាលមួយ ដែលមនុស្សសាមញ្ញទាំងឡាយនៅតែគោរពប្រតិបត្តិនៅឡើយ គឺពេលគេក្រោកពីដេកនៅពេលព្រឹក មុនដំបូងបង្អស់គេលាងមុខ ខ្ពុរមាត់ រួចហើយគេឱនក្រាបឆ្ពោះទៅទិសទាំងប្រាំមួយ គឺទិសខាងកើត ខាងលិច ខាងត្បូង ខាងជើង ខាងលើ ខាងក្រោម សុំកុំឲ្យមានទុក្ខមកពីទិសទាំងនោះ ហើយសុំឲ្យបានប្រកបសេចក្តីសុខពេញមួយថ្ងៃ។

ប៉ុន្តែ កិច្ចនេះខុសនឹងសេចក្តីទូន្មានរបស់ព្រះពុទ្ធ។ ព្រះពុទ្ធប្រដៅយើងឲ្យធ្វើគារវកិច្ចទៅទិសទាំងប្រាំមួយនៃសច្ចធម៌ ហើយឲ្យប្រព្រឹត្តតាមដោយគតិបណ្ឌិត និងគុណធម៌ យ៉ាងនេះយើងនឹងចៀសផុតពីទុក្ខទាំងឡាយ។

ដើម្បីយាមការពារមាត់ទ្វារនៃទិសទាំងប្រាំមួយ បុគ្គលត្រូវបំបាត់ចោលអំពើពុករលួយបួនប្រការ ត្រូវត្រួតពិនិត្យបាបចិត្តបួនប្រការ ត្រូវខ្ទប់រន្ធទាំងប្រាំមួយ ដែលបណ្តាលឲ្យខូចបង់ទ្រព្យសម្បត្តិ។

អំពើលាមកបួនប្រការនោះគឺ កាប់សម្លាប់ លួចប្លន់ ផិតក្បត់ បោកបញ្ឆោត។

បាបចិត្តបួនប្រការនោះគឺ ចិត្តលោភលន់ ចិត្តក្រោធខឹង ចិត្តឆ្កួតលេលា ចិត្តខ្លាចញញើត។

រន្ធប្រាំមួយដែលបណ្តាលឲ្យខូចបង់ទ្រព្យនោះគឺៈ សេពទឹកស្រវឹង ហើយប្រព្រឹត្តអំពើឆ្កួតលេលា ដើរលេងយប់ជ្រៅ វក់ក្នុងការកំសាន្តនឹងតន្ត្រីល្ខោន ប្រព្រឹត្តល្បែងភ្នាល់ សេពគប់នឹងបាបមិត្ត ធ្វេសប្រហែសករណីយកិច្ចរបស់ខ្លួន។

ក្រោយពីបានបំបាត់ចោលអំពើពុករលួយទាំងបួន ចៀសវាងបាបចិត្តទាំងបួន ចុករន្ធបំផ្លាញទ្រព្យទាំងប្រាំមួយរួចហើយ ពុទ្ធសាសនិកទាំងឡាយឱនក្រាបធ្វើគារវកិច្ចទៅទិសទាំងប្រាំមួយនៃសច្ចធម៌។

តើទិសទាំងប្រាំមួយនៃសច្ចធម៌នោះជាអ្វីខ្លះទៅ ? ទិសខាងកើតជាផ្លូវសម្រាប់មាតាបិតានិងបុត្រ ទិសខាងត្បូងជាផ្លូវសម្រាប់គ្រូ និងសិស្ស ទិសខាងលិចជាផ្លូវសម្រាប់ស្វាមី និងភរិយា ទិសខាងជើងជាផ្លូវសម្រាប់បុគ្គល និងមិត្ត ទិសខាងក្រោមជាផ្លូវសម្រាប់ចៅហ្វាយ និងខ្ញុំកំដរ ទិសលើជាផ្លូវសម្រាប់អ្នកកាន់ពុទ្ធសាសនា។

កូនត្រូវគោរពឪពុកម្តាយ បំពេញកិច្ចដែលគាត់សង្ឃឹមចង់បានពីខ្លួន ត្រូវបម្រើគាត់ ជួយធ្វើកិច្ចការគាត់ រក្សាចំណងគ្រួសារ ការពារទ្រព្យសម្បត្តិគ្រួសារ ហើយទីបំផុតត្រូវធ្វើបុណ្យជូនគាត់ នៅពេលគាត់ស្លាប់ទៅ។

មាតាបិតាត្រូវបំពេញកិច្ចប្រាំប្រការចំពោះបុត្រភ្វា គឺចៀសវាងអំពើអាក្រក់ ធ្វើខ្លួនឲ្យបានជាគំរូល្អដល់កូន ផ្តល់ចំណេះវិជ្ជាដល់កូន រៀបអាពាហ៍ពិពាហ៍ឲ្យកូន ចែកទ្រព្យ

សម្បត្តិឲ្យកូននៅពេលដែលត្រូវចែក។ បើមាតាបិតា និងបុត្រ ប្រតិបត្តិតាមច្បាប់វិន័យនេះ គ្រួសារទាំងមូល នឹងបានរស់នៅ ក្នុងសុខសន្តិភាពជានិច្ច។

សិស្សត្រូវក្រោកឈរជានិច្ច នៅពេលលោកគ្រូដើរចូល មក ត្រូវគោរពបម្រើលោកគ្រូ ត្រូវស្តាប់បង្គាប់បទបញ្ជាលោក គ្រូ ត្រូវដឹងគុណលោកគ្រូ ត្រូវធ្វើតាមសេចក្តីប្រៀនប្រដៅរបស់ លោកគ្រូ ដោយគោរព។

ក្នុងពេលជាមួយគ្នានេះ គ្រូត្រូវធ្វើខ្លួនឲ្យបានត្រឹមត្រូវ ដើម្បីជាគំរូល្អដល់សិស្ស ត្រូវបញ្ជូនចំណេះវិជ្ជា ដែលខ្លួនបាន រៀនចេះមក ឲ្យបានត្រឹមត្រូវដល់សិស្ស ត្រូវប្រើប្រាស់មធ្យោ-បាយត្រឹមត្រូវក្នុងការពន្យល់ណែនាំសិស្ស ហើយខំធ្វើឲ្យសិស្ស បានប្រកបកិត្តិយស មិនត្រូវភ្លេចការពារសិស្សទប់ទល់នឹង អំពើអាក្រក់ ក្នុងករណីដែលអាចធ្វើបាន។ បើគ្រូ និងសិស្ស ប្រតិបត្តិតាមច្បាប់វិន័យនេះ ការរួបរួមគ្នារវាងគ្រូ និងសិស្ស នឹងមានដំណើរស្រួល។

ប្តីត្រូវទុកដាក់ប្រពន្ធដោយគោរព ដោយចេះគួរសម ដោយមានស្វាមីភក្តិ។ ប្តីត្រូវទុកកិច្ចការក្នុងផ្ទះឲ្យប្រពន្ធហើយ

ពេលខ្វះ ត្រូវបំពេញសេចក្តីត្រូវការរបស់ប្រពន្ធ។ នៅពេលព្រមគ្នានេះ ប្រពន្ធត្រូវចេះខ្វល់ខ្វាយនឹងកិច្ចការក្នុងផ្ទះ ត្រូវចេះប្រើខ្ញុំកំដរដោយគតិធម៌ ត្រូវរក្សាលក្ខណៈសម្បត្តិរបស់ខ្លួនឲ្យបានជាប្រពន្ធល្អ មិនត្រូវខ្ជះខ្ជាយទ្រព្យសម្បត្តិដែលប្តីរកបានមក ត្រូវរៀបចំផ្ទះឲ្យបានស្អាតស្អំ ត្រូវមានចិត្តស្មោះត្រង់។ បើគេប្រតិបត្តិតាមច្បាប់វិន័យនេះ គ្រួសាររបស់គេនឹងបានស្គាល់សេចក្តីសុខ ហើយការឈ្លោះទាស់ទែងគ្នា មិនអាចកើតឡើងបានឡើយ។

ច្បាប់វិន័យរវាងមិត្តនឹងមិត្តគឺ ត្រូវចេះសម្រុបចិត្តគ្នាទៅវិញទៅមក។ អ្នកម្ខាងត្រូវចេះផ្តល់ដល់អ្នកម្ខាងទៀតនូវរបស់ដែលគ្នាខ្វះខាត ត្រូវចេះផ្តល់ប្រយោជន៍ដល់គ្នា ត្រូវប្រើតែវាចាស្មោះគួរជាទីស្រឡាញ់រវាងគ្នា។

គេត្រូវជួយឃិតយោងមិត្តរបស់គេ កុំឲ្យធ្លាក់ទៅក្នុងផ្លូវអាក្រក់។ គេត្រូវការពារទ្រព្យសម្បត្តិមិត្តរបស់គេហើយជួយដោះទុក្ខគ្នា។ បើមិត្តមានគ្រោះកាច គេត្រូវជួយសង្គ្រោះគ្នាហើយជួយទ្រទ្រង់គ្រួសារគ្នាថែមទៀតផង បើសិនជាការចាំបាច់។ យ៉ាងនេះ គេនឹងអាចរក្សាមិត្តភាពរវាងគ្នានឹងគ្នា

ហើយគេនឹងបានស្គាល់សេចក្ដីសុខចម្រើនទាំងអស់គ្នាជាលំដាប់។

ចៅហ្វាយត្រូវកាន់វិន័យប្រាំប្រការចំពោះខ្ញុំបម្រើ គឺត្រូវប្រគល់កិច្ចការឲ្យខ្ញុំបម្រើធ្វើទៅតាមសមត្ថភាពរបស់គ្នា ត្រូវឲ្យរង្វាន់ដល់ខ្ញុំបម្រើឲ្យបានសមរម្យ ត្រូវមើលថែរក្សាខ្ញុំបម្រើនៅពេលគ្នាមានជំងឺ ត្រូវចែករំលែករបស់ជាទីគាប់ចិត្តដល់ខ្ញុំបម្រើ ត្រូវអនុញ្ញាតឲ្យខ្ញុំបម្រើបានឈប់សម្រាកតាមត្រូវការ។

ខ្ញុំបម្រើត្រូវកាន់វិន័យប្រាំគឺ: ត្រូវក្រោកមុនម្ចាស់ហើយដេកក្រោយម្ចាស់ ត្រូវស្មោះត្រង់នឹងម្ចាស់ជានិច្ច ត្រូវខំធ្វើកិច្ចការរបស់ខ្លួនឲ្យបានល្អ ត្រូវខំធ្វើយ៉ាងណាកុំឲ្យម្ចាស់ខូចកិត្តិនាម។ បើគេប្រតិបត្តិតាមច្បាប់វិន័យនេះ គេនឹងបានសុខហើយការទាស់ទែងគ្នារវាងចៅហ្វាយនឹងខ្ញុំបម្រើមិនអាចនឹងកើតឡើងបានឡើយ។

ពុទ្ធសាសនិកទាំងឡាយ ត្រូវជួយជម្រុញឲ្យក្រុមគ្រួសាររបស់ខ្លួនប្រតិបត្តិតាមសេចក្ដីទូន្មានរបស់ព្រះពុទ្ធ។ គេត្រូវចេះគោរព យកចិត្តទុកដាក់នឹងគ្រូអាចារ្យបង្រៀនព្រះធម៌។ គេ

ត្រូវចេះគួរសមនឹងគ្រូអាចារ្យ។ គេត្រូវស្តាប់បង្គាប់ប្រតិបត្តិតាមសេចក្តីប្រៀនប្រដៅរបស់គ្រូអាចារ្យ ហើយដឹងគុណលោកជានិច្ច។

គ្រូអាចារ្យអ្នកបង្រៀនព្រះធម៌ ត្រូវយល់ព្រះធម៌ឲ្យបានត្រឹមត្រូវ ត្រូវចៀសវាងការបកស្រាយខុស ត្រូវពន្យល់បញ្ជាក់អំពីអំពើល្អ ត្រូវខំដឹកនាំអ្នកមានជំនឿលើសាសនាឲ្យដើរតាមផ្លូវល្អ។ កាលណាបើក្រុមគ្រួសារណាមួយដើរតាមផ្លូវល្អនេះ ហើយជឿទុកចិត្តលើសេចក្តីទូន្មានពិតប្រាកដ ក្រុមគ្រួសារនោះនឹងបានប្រកបសុភមង្គល។

អ្នកដែលឱនក្រាបធ្វើគារវកិច្ចទៅទិសទាំងប្រាំមួយ គឺមិនមែនដើម្បីឲ្យបានរួចផុតពីទុក្ខ ដែលមកពីខាងក្រៅនោះទេ។ គេប្រព្រឹត្តយ៉ាងនេះ ជាការប្រុងប្រយ័ត្ន ដើម្បីការពារខ្លួនទប់ទល់នឹងបាបកម្ម ដែលប្រុងនឹងកើតមាននៅក្នុងចិត្តរបស់គេផ្ទាល់។

2. បុគ្គលរាល់រូប ត្រូវចេះមើលមនុស្សដែលគួរសេពគប់ និងមនុស្សដែលមិនគួរសេពគប់។

មនុស្សដែលមិនគួរសេពគប់គឺ មនុស្សលោភ និយាយច្រើន បញ្ឆោត បង្ខិនបង្ខោច។

មនុស្សដែលគួរសេពគប់គឺ មនុស្សចេះជួយគ្នា មនុស្សមានចិត្តចេះចែករំលែកសេចក្តីសប្បាយ និងសេចក្តីព្រួយរវាងគ្នានឹងគ្នា មនុស្សចេះឲ្យដំបូន្មានល្អដល់គ្នា មនុស្សមានចិត្តជាមិត្ត។

មិត្តពិតប្រាកដ ដែលអាចសេពគប់បាន តែងតែដើរតាមគន្លងផ្លូវសុចរិតជានិច្ច។ គេមានចិត្តចង់ឲ្យតែមិត្តរបស់គេ បានប្រកបសុភមង្គល គេចេះលួងលោមសម្រាលទុក្ខមិត្ត ចេះជួយមិត្តនៅពេលមានធុរៈ ចេះលាក់ការសម្ងាត់របស់មិត្ត ចេះឲ្យដំបូន្មានល្អដល់មិត្ត។

មិត្តរបៀបនេះ ពិបាករកណាស់ ដូច្នេះត្រូវតែខំប្រឹងខ្លួនឯងឲ្យបានទៅជាមិត្តរបៀបនេះ។ ដូចជាព្រះអាទិត្យកំដៅដីមានជីជាតិ មិត្តល្អភ្លឺចែងចាំងនៅក្នុងសង្គម ដោយសារអំពើល្អរបស់គេ។

3. ចំពោះសេចក្តីស្រឡាញ់ថ្នាក់ថ្នមបីបាច់ថែរក្សា ដែលមាតា

បិតាមានទៅលើបុត្រ  បុត្រមិនអាចសងគុណរួចទេទោះបីជាគេអាចបញ្ជិះឪពុកលើស្មាស្តាំ  ហើយបញ្ជិះម្តាយលើស្មាឆ្វេងរបស់គេ រាប់រយឆ្នាំក៏ដោយ។

ទោះបីជាគេអាចផ្ងូតទឹកមាតាបិតា ដោយទឹកអប់ផ្កាក្រអូបអស់រាប់រយឆ្នាំក៏ដោយ។ ទោះបីជាគេអាចបម្រើគាត់ក្នុងភាពជាកូនល្អឥតខ្ចោះក៏ដោយ  ទោះបីជាគេអាចធ្វើឲ្យគាត់បានសោយរាជ្យជាស្តេចផែនដីក៏ដោយ ទោះបីជាគេអាចយកសម្បត្តិទាំងពិភពលោកមកជូនគាត់ដ៏ដោយ ក៏គេមិនអាចសងបំណុលគាត់ឲ្យបានគ្រប់គ្រាន់ដែរ។

ប៉ុន្តែ បើគេដឹកនាំឪពុកម្តាយគេឆ្ពោះទៅរកព្រះពុទ្ធពន្យល់គាត់ឲ្យជឿសាសនាព្រះពុទ្ធ  បញ្ចុះបញ្ចូលគាត់ឲ្យវៀរចាកផ្លូវអាក្រក់ហើយដើរតាមផ្លូវត្រូវ ដឹកនាំគាត់ឲ្យលះបង់ការលោភលន់ ហើយឲ្យគាត់ចេះសប្បាយរីករាយ ក្នុងការធ្វើទានកុសលនោះគេអាចសងបំណុលគាត់រួចជាពិតប្រាកដ។

4. គ្រួសារគឺជាកន្ទេងមួយ  ដែលចិត្តប្រជុំទាក់ទងគ្នា។ បើចិត្ត ចេះស្រឡាញ់រួបរួមគ្នា គ្រួសារនឹងបានល្អប្រិមប្រិយដូចជាសួនដែលមានបុប្ផារីកស្គុសស្គាយ។ ប៉ុន្តែបើចិត្តមិនចូល

សម្រុងគ្នាទេ គឺដូចជាខ្យល់ព្យុះដែលបក់រំលើងសួនឧទ្យាន។

បើមានការទាស់ទែងគ្នា កើតឡើងក្នុងគ្រួសារ មិនត្រូវដាក់កំហុសទៅអ្នកក្រៅទេ ត្រូវពិនិត្យកែតម្រង់ចិត្តរបស់ខ្លួនឯងផ្ទាល់។

5. ក្នុងបូរាណកាលដ៏យូរលង់មកហើយ មានបុរសម្នាក់មានជំនឿក្នុងសាសនាយ៉ាងមុតមាំ។ ឪពុកបានស្លាប់ចោលទៅតាំងពីបុរសនោះនៅក្មេងវ័យ។ បុរសរស់នៅតែពីរនាក់នឹងម្ដាយដោយសុខសាន្ត។ ក្រោយមក បុរសក៏មានប្រពន្ធ។

មុនដំបូង គ្រួសារនេះរស់នៅជាមួយគ្នាដោយសុខសាន្ត តែបន្ទាប់មក ដោយហេតុទាស់សម្ដីគ្នាបន្តិចបន្តួច ប្រពន្ធនឹងម្ដាយក្មេក ក៏ទៅជាស្អប់គ្នាទៅវិញទៅមក។ ការស្អប់គ្នានេះរីកធំឡើងៗ រហូតដល់ទីបំផុត ម្ដាយបានចាកចេញពីគូស្រករក្មេងនេះទៅរស់នៅតែម្នាក់ឯងទៅ។

ក្រោយពីម្ដាយក្មេកចេញបាត់ទៅ គូស្រករក្មេងនោះបានកូនប្រុសមួយ។ ប្រពន្ធក្មេងតែងតែ រំលឹកនិយាយសម្អប់ពីម្ដាយក្មេកថា: «ម៉ែ គាត់អំពល់ទុក្ខយើងគ្រប់ពេលវេលា។

*ពេលដែលគាត់នៅជាមួយយើង យើងមិនដែលបានសប្បាយម្ដងណាទេ។ គ្រាន់តែគាត់ចេញទៅបាត់បានបន្តិច យើងបានសប្បាយដោយបានកូនប្រុសមួយយ៉ាងនេះ»។*

*ពាក្យនិយាយសម្ពប់នេះ បានឮទៅដល់ម្ដាយក្មេក។ គាត់ខឹងជាខ្លាំង ហើយថ្លែងថាៈ «ការបណ្ដេញម្ដាយក្មេកឲ្យចាកចេញពីផ្ទះ ត្រូវបានបណ្ដាលឲ្យមានព្រឹត្តិការណ៍ដ៏ជាទីសប្បាយរីករាយយ៉ាងនេះ ឃើញថាលោកនេះ វាត្រឡប់ត្រឡិនអស់ហើយ ! ភាពត្រឹមត្រូវតាមគន្លងធម៌ ត្រូវបានវិនាសសូន្យពីលោកនេះហើយ !»។*

*«នៅពេលនេះ យើងគួរតែធ្វើបុណ្យ បញ្ជូនកុសលឲ្យខ្មោចនៃភាពត្រឹមត្រូវតាមគន្លងធម៌នេះ!»។ ដូចជាស្រីឆ្កួតម្ដាយក្មេកដើរតម្រង់ទៅផ្នូរខ្មោច ដើម្បីធ្វើបុណ្យបញ្ជូនកុសលដល់ខ្មោចនៃភាពត្រឹមត្រូវតាមគន្លងធម៌។*

*ព្រះឥន្ទ្រទ្រង់ជ្រាបរឿងនេះ ក៏ចុះមកប្រត្យក្សនៅមុខម្ដាយក្មេក ហើយសាកល្បងពន្យល់គាត់ គ្រប់បែបយ៉ាងតែជាការឥតប្រយោជន៍។*

ព្រះឥន្ទ្រ ក៏មានព្រះបន្ទូលថាៈ «បើអញ្ចឹង យើងជុត ទារកនិងម្ដាយវាឲ្យស្លាប់បង់។ យើងធ្វើដូច្នេះ តើអ្នកពេញចិត្ត ឬទេ?»។

នៅពេលឮព្រះឥន្ទ្រមានព្រះបន្ទូលដូច្នេះ ម្ដាយក្មេកក៏ ភ្ញាក់រលឹកដឹងកំហុសរបស់ខ្លួន ហើយក្រាបសំពះសុំទោសព្រះ ឥន្ទ្រអង្វរសុំឲ្យទុកជីវិតឲ្យទារកនិងម្ដាយ។ ក្នុងខណៈនោះដែរ ឯខាងប្រពន្ធប្ដី ក៏ភ្ញាក់រលឹកយល់នូវអំពើអយុត្តិធម៌របស់ខ្លួន ចំពោះម្ដាយចាស់ ហើយនាំគ្នាទៅរកគាត់ដល់ផ្នូរខ្មោច។ ព្រះ ឥន្ទ្រក៏ផ្សះផ្សាអ្នកទាំងនោះ។ បន្ទាប់ពីពេលនោះមកអ្នកទាំង នោះក៏បានរស់នៅជាមួយគ្នា ដោយសុខសាន្ត។

ភាពត្រឹមត្រូវតាមគន្លងធម៌ មិនវិនាសបាត់រហូតទេ បើគេ មិនបាត់សតិរបស់គេផ្ទាល់។ ចួនកាល ភាពត្រឹមត្រូវតាមគន្លង ធម៌នេះហាក់ដូចជាវិនាសបាត់ទៅ តែតាមពិត វាមិនដែល វិនាសបាត់ទេ។ កាលណាភាពត្រឹមត្រូវតាមគន្លងធម៌នេះ ហាក់ដូចជាវិនាសបាត់ គឺដោយសារតែយើងត្រូវបាត់បង់ភាព ត្រឹមត្រូវនៃសតិរបស់យើងផ្ទាល់នោះឯង។

ចិត្តមិនស្របគ្នា បណ្ដាលឲ្យកើតមានភយន្តរាយ ជាញឹកញយ។ ការទាស់ទែងគ្នាជាធម្មតាតូចមួយ អាចនាំឲ្យមានទុក្ខធំ។ គេត្រូវប្រយ័ត្នជានិច្ច ចៀសវាងនូវការទាស់ចិត្តគ្នានេះ នៅក្នុងជីវិតគ្រួសារ។

6. ក្នុងជីវិតគ្រួសារ បញ្ហាចាយវាយជារឿងរាល់ថ្ងៃត្រូវចេះគិតគូរលៃលកឲ្យបានហ្មត់ចត់ជាទីបំផុត។ សមាជិកគ្រួសារម្នាក់ៗត្រូវខំធ្វើការឲ្យម៉ឺងម៉ាត់ ដូចជាសត្វស្រមោចដែលរវៀសរវៃសត្វឃ្មុំដែលរវល់ជានិច្ច។ អ្នកណាក៏ដោយ មិនត្រូវដេកពឹងកម្លាំងអ្នកឯទៀតទេ មិនត្រូវសង្ឃឹមលើអំណោយទានពីអ្នកឯទៀតទេ។

ម្យ៉ាងទៀត គេមិនត្រូវគិតទុករបស់ ដែលរកបានមកសម្រាប់តែខ្លួនឯងម្នាក់ទេ។ គេត្រូវចេះចែករំលែកមួយភាគឲ្យទៅអ្នកឯទៀត ទុកមួយភាគសម្រាប់ពេលខ្វះខាត ទុកមួយភាគសម្រាប់ការត្រូវការនៃសង្គម ហើយទុកមួយភាគទៀតសម្រាប់ធ្វើបុណ្យទាន។

គេត្រូវរំលឹកគិតជានិច្ចថា នៅក្នុងលោកនេះ គ្មានអ្វីដែលអាចហៅបានថាជារបស់ឯកសិទ្ធិ សម្រាប់តែខ្លួនឯងម្នាក់នោះបានទេ។ អ្វីក៏ដោយ ដែលគេរកបានមក សុទ្ធតែជារបស់ដែលកើតមកអំពីការផ្សំបញ្ចូលគ្នានៃហេតុនិងល័ក្ខខ័ណ្ឌ។ គេអាចរក្សាទុករបស់នោះ បានតែក្នុងមួយរយៈវេលាប៉ុណ្ណោះ។ ហេតុដូច្នេះ គេមិនត្រូវប្រើប្រាស់របស់នោះ ដោយមានចិត្តគិតទុកសម្រាប់តែខ្លួនឯងម្នាក់ ឬក្នុងគោលបំណងអាក្រក់មិនសមរម្យនោះទេ។

7. នៅពេលដែលព្រះនាង **សាមាវតី** ព្រះអគ្គមហេសីព្រះបាទ **ឧទេន** ទ្រង់ប្រទានស្បង់ប្រាំរយដល់**ព្រះអានន្ទ** **ព្រះអនន្ទ**ទ្រង់ទទួលយកដោយព្រះទ័យត្រេកអរជាទីបំផុត។

ព្រះមហាក្សត្រ នៅពេលបានជ្រាបរឿងនេះ ទ្រង់មានការសង្ស័យទៅលើ**ព្រះអានន្ទ**ថាមិនស្មោះត្រង់ព្រះអង្គក៏ត្រាស់សួរ**ព្រះអានន្ទ**ថា តើយកស្បង់ទាំងប្រាំរយនោះទៅធ្វើអ្វី?។

**ព្រះអានន្ទ**ឆ្លើយថា: «សូមព្រះមហាក្សត្រជ្រាប! ភិក្ខុសង្ឃ

ជាច្រើន ស្បៀកស្បង់រហែករយ៉ីរយ៉ៃ។ ទូលព្រះបង្គំយកស្បង់ទាំងនេះ ទៅចែកពួកភិក្ខុសង្ឃនោះ»។

«តើអ្នកយកស្បង់ចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកស្បង់ចាស់ទៅធ្វើកម្រាលគ្រែដេក»

«តើអ្នកយកកម្រាលចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកកម្រាលចាស់ទៅធ្វើខ្នើយកើយ»

«តើអ្នកយកខ្នើយចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកខ្នើយចាស់ទៅធ្វើកម្រាលរនាបក្តារ»

«តើអ្នកយកកម្រាលរនាបចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកកម្រាលរនាបចាស់ទៅធ្វើកន្ទបជូតជើង»

«តើអ្នកយកកន្ទបជូតជើងចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកកន្ទបជូតជើងចាស់ទៅធ្វើកន្ទបជូតរនាប»

«តើអ្នកយកកន្ទបជូតរនាបចាស់ទៅធ្វើអ្វី ?»

«ព្រះករុណាតម្កល់លើត្បូង! យើងខ្ញុំហែកកន្ទបជូតរនាបចាស់នោះជាចំណែកតូចៗ យកទៅលាយនឹងភក់ ហើយយកទៅបូកជញ្ជាំងកុដិ»។

វត្ថុនីមួយៗ ដែលយើងបានមក យើងត្រូវចេះប្រើប្រាស់វា

ដោយផ្ចិតផ្ចង់ ឲ្យបានជាប្រយោជន៍ ពីព្រោះវត្ថុនោះមិនមែនជារបស់យើងរហូតទេ យើងបានវាមកជាបណ្ដោះអាសន្នតែប៉ុណ្ណោះ។

8. ដំណើររួមរស់នៃគូស្វាមីភរិយា មិនមែនសម្រាប់តែសេចក្ដីសុខស្រួល ទាំងផ្លូវកាយទាំងផ្លូវចិត្ត នៅក្នុងផ្ទះមួយជាមួយគ្នាតែប៉ុណ្ណោះទេ។ គូស្វាមីភរិយា ត្រូវបេះធៀតទាញយកប្រយោជន៍អំពីភាពស្និទ្ធស្នាលនៃការរួមរស់ជាមួយគ្នានេះ ជួយណែនាំគ្នាឲ្យបណ្ដុះបណ្ដាលចិត្តមានជំនឿជ្រះថ្លាក្នុងព្រះសាសនា។

មានស្វាមីភរិយាចំណាស់មួយគូ ដែលជាប់ឈ្មោះថាជាគូស្វាមីភរិយាឧត្តម បានទៅថ្វាយបង្គំព្រះពុទ្ធ ហើយទូលសួរថា «ព្រះពុទ្ធជាម្ចាស់ ! យើងខ្ញុំព្រះករុណាបានគ្នាជាប្ដីប្រពន្ធក្រោយពេលដែលបានស្គាល់គ្នាតាំងពីនៅក្មេងដូចគ្នា ហើយយើងខ្ញុំស្គាល់តែសេចក្ដីសុខ ពុំដែលមានរឿងសៅហ្មងនឹងគ្នាម្ដងណាទេ។ សូមព្រះអង្គមេត្តាពន្យល់ប្រាប់យើងខ្ញុំផង តើយើងខ្ញុំត្រូវធ្វើយ៉ាងណា ដើម្បីអាចនឹងបានជួបគ្នាទៀត នៅជាតិក្រោយ»។

ព្រះពុទ្ធ ទ្រង់មានពុទ្ធដីកាប្រកបដោយគតិបណ្ឌិតថា: «បើអ្នកទាំងពីរមានជំនឿសាសនាដូចគ្នាបេះបិទ បើអ្នកទាំងពីរទទួលយកសេចក្តីទូន្មាននៃព្រះពុទ្ធសាសនាតាមរបៀបដូចគ្នាបេះបិទ បើអ្នកទាំងពីរសាងកុសលទានដូចគ្នា ហើយបានប្រកបនូវបុណ្យបារមីដូចគ្នា ទៅជាតិក្រោយទៀតអ្នកទាំងពីរនឹងបានប្រកបដោយចិត្តដូចគ្នាទៀតជាមិនខាន»។

9. ចំពោះផ្លូវទៅកាន់ពន្លឺត្រាស់ដឹង គ្មានការប្រកាន់ភេទស្រីឬប្រុសទេ។ ស្ត្រីក៏ដោយ កាលណាមានចិត្តស្វែងរកពន្លឺត្រាស់ដឹង នឹងបានជាវីរនារីមួយរូបនៃភាពបរិសុទ្ធនេះ។

ព្រះនាង**មល្លិកា** បុត្រីស្តេច**ប្រសេនជិត** និងជាអគ្គមហេសីព្រះរាជាអយុធ្យា ជាវីរនារីមួយរូប។ ព្រះនាងមានជំនឿមុតមាំនឹងព្រះពុទ្ធសាសនា ព្រះនាងបានធ្វើសច្ចាធិដ្ឋានជប់ប្រការនឹងព្រះពុទ្ធ ដូចតទៅនេះ៖

«ព្រះពុទ្ធជាម្ចាស់ ! រហូតដល់នាងខ្ញុំបានសម្រេចនូវពន្លឺត្រាស់ដឹង នាងខ្ញុំនឹងមិនប្រព្រឹត្តរំលងនឹងធម្មវិន័យឡើយ

នាងខ្ញុំនឹងមិនក្រអឺតក្រអោងនឹងអ្នកមានវ័យច្រើនជាងនាងខ្ញុំ នាងខ្ញុំនឹងមិនខឹងនឹងអ្នកណាម្នាក់ឡើយ»។

«នាងខ្ញុំនឹងមិនច្រណែនឫស្យានឹងអ្នកឯទៀត ហើយមិនប្រាថ្នាចង់បានទ្រព្យសម្បត្តិអ្នកទាំងនោះឡើយ។ នាងខ្ញុំនឹងមិនប្រកាន់ចិត្តអត្តទត្តឡើយ។ នាងខ្ញុំនឹងខំធ្វើឲ្យអ្នកក្រីក្របានសប្បាយរីករាយ ដោយប្រើប្រាស់វត្ថុទាំងឡាយដែលនាងខ្ញុំមាន ហើយនាងខ្ញុំនឹងមិនប្រាថ្នាប្រមូលរបស់អស់ទាំងនោះទុកសម្រាប់តែខ្លួននាងខ្ញុំម្នាក់ឡើយ។

«នាងខ្ញុំនឹងទទួលមនុស្សគ្រប់ចំពូក ដោយរាក់ទាក់គួរសម នឹងធ្វើទាននូវវត្ថុទាំងឡាយណាដែលអ្នកទាំងនោះត្រូវការជាចាំបាច់។ នាងខ្ញុំនឹងរាប់អានអ្នកទាំងនោះដោយស្មោះនាងខ្ញុំនឹងខំប្រព្រឹត្តល្អចំពោះអ្នកទាំងនោះ ដោយមិនលំអៀងទៅខាងណាមួយឡើយ»។

«បើនាងខ្ញុំឃើញអ្នកណាម្នាក់រស់នៅក្នុងភាពកំព្រាឯកាក្នុងពន្ធនាគារ ឬក្នុងភាពមានទុក្ខដោយជំងឺ ឬដោយការព្រួយបារម្ភផ្សេងទៀត នាងខ្ញុំនឹងខឹតខំជួយអ្នកនោះ ឲ្យបានសប្បាយ

រីករាយ ដោយពន្យល់អ្នកនោះ ឲ្យយល់នូវហេតុ និងច្បាប់វិន័យ»។

«បើនាងខ្ញុំឃើញអ្នកណាម្នាក់ ចាប់សត្វយកមកធ្វើបាប ឬប្រព្រឹត្តបំពាននឹងច្បាប់វិន័យ នាងខ្ញុំនឹងធ្វើទោសអ្នកនោះ បើសិនជាអ្នកនោះសមតែទទួលទោស នាងខ្ញុំនឹងស្តីប្រដៅ បើសិនជាអ្នកនោះសមត្រឹមតែទទួលការប្រៀនប្រដៅ ហើយនាងខ្ញុំនឹងខិតខំកែកំហុសអ្នកនោះ យ៉ាងអស់សមត្ថភាពនាងខ្ញុំ»។

«នាងខ្ញុំនឹងមិនភ្លេចស្តាប់សេចក្តីទូន្មានត្រឹមត្រូវ ដោយនាងខ្ញុំដឹងថា បើគេធ្វេសប្រហែសសេចក្តីទូន្មានត្រឹមត្រូវ គេនឹងឃ្លាតចាកពីសេចក្តីពិតយ៉ាងឆាប់រហ័ស ហើយយ៉ាងនេះគេមុខតែមិនបានសម្រេចពន្លឺត្រាស់ដឹងជាពិតប្រាកដ»។

បន្ទាប់មកទៀត ព្រះនាងបានធ្វើសច្ចាធិដ្ឋានបីប្រការដើម្បីជួយសង្គ្រោះអ្នកក្រីក្រ។ «ទីមួយ នាងខ្ញុំនឹងខំធ្វើឲ្យជនទាំងអស់បានសុខសន្តិភាព។ នាងខ្ញុំជឿថា ទៅមុខទៀតនាងខ្ញុំមានជីវិតបែបណាក៏ដោយ ក៏សេចក្តីប្រាថ្នានេះនឹងបានជាឫសនៃកុសលសម្រាប់ការបានត្រាស់ដឹងនូវធម៌វិសុទ្ធ»។

«ទីពីរ កាលណានាងខ្ញុំបានទទួលការត្រាស់ដឹងនូវធម៌វិសុទ្ធនេះហើយ នាងខ្ញុំនឹងយកទៅពន្យល់អ្នកឯទៀត ដោយមិនគិតដល់ការនឿយហត់របស់នាងខ្ញុំឡើយ»។

«ទីបី នាងខ្ញុំនឹងរក្សាការពារធម៌វិសុទ្ធនេះ ទោះបីនាងខ្ញុំត្រូវបូជារូបកាយ ជីវិត ឬទ្រព្យសម្បត្តិរបស់នាងខ្ញុំ ក៏ដោយ»។

ន័យពិតនៃជីវិតគ្រួសារគឺ ឱកាស ដែលសមាជិកគ្រួសារម្នាក់ៗ ជួយជំរុញគ្នា ជ្រោមជ្រែងគ្នាក្នុងដំណើរផ្លូវទៅកាន់ពន្លឺត្រាស់ដឹង។ ស្ត្រីប្រភេទណាក៏ដោយ ក៏អាចបានជាសាវ័កវិសេសវិសាល របស់ព្រះពុទ្ធ ដូចជាព្រះនាង**មល្លិកា**ដែរ បើសិនស្រីនោះមាន ប្រាជ្ញាស្វែងរកពន្លឺត្រាស់ដឹងដូចព្រះនាង ហើយធ្វើសច្ចាធិ-ដ្ឋានដូចព្រះនាង។

# ចំពូកទី ២

# កសាងដែនដីព្រះពុទ្ធ

## I

## ភាពសុខដុមនៃសហគមន៍ពុទ្ធសាសនិក

1. *ចូរយើងនឹកស្មានមើលទៅក្នុងសមុទ្រខ្សាច់មួយដែលធ្លាក់ក្នុងភាពងងឹតស្លុង ហើយមានមនុស្សជាច្រើនវង្វេងវិលវល់ មើលអ្វីពុំឃើញ នៅក្នុងទោនោះ។*

*ជាធម្មតា មនុស្សទាំងនោះនឹងមានការភ័យភិត រុញច្រានគ្នាទៅវិញទៅមក ដោយមិនស្គាល់គ្នាឡើយ។ មនុស្សទាំងនោះដើរប្រវេប្រវាលែងចេះឈប់ វង្វេងវង្វាន់គ្នាទៅដោយខ្លួនទីទៃៗ។ គឺពិតជាទិដ្ឋភាពមួយសែនវេទនា។*

*នៅពេលនោះ មានវីរបុរសម្នាក់ កាន់ចន្លុះមួយនៅដៃ បញ្ចេញខ្លួនឲ្យឃើញឡើង បណ្តាលឲ្យភ្លឺគ្រប់ទិសទី។*

*មនុស្សម្នាទាំងឡាយ ដែលមកទល់ពេលនេះ ប្រវេប្រវារស្ទាបក្នុងទីងងឹត ក៏បានភ្លឺស្វាងឡើង ហើយក្រឡេកមើលជុំ*

វិញខ្លួន។ គេសម្គាល់ឃើញមានមនុស្សដូចគេដែរនៅជុំវិញគេ គេក៏ស្រែកហ៊ោសប្បាយរត់ទៅឱបគ្នា ហើយនិយាយកាន់គ្នាទៅវិញទៅមកដោយភាពស្និទ្ធស្នាល។

សមុទ្រខ្សាច់នោះ គ្មានអ្វីក្រៅពីជីវិតមនុស្សលោកនេះទេ។ ភាពងងឹតគឺសេចក្ដីល្ងង់ខ្លៅនោះឯង។ មនុស្សដែលគ្មានពន្លឺគតិបណ្ឌិតនៅក្នុងចិត្ត ត្រូវបានវង្វេងវង្វាន់នៅក្នុងសភាពតែលតោលម្នាក់ឯង និងក្នុងសភាពភ័យភិត។ មនុស្សទាំងនោះ កើតមកម្នាក់ឯង ហើយស្លាប់ទៅវិញម្នាក់ឯង។ មនុស្សទាំងនោះ មិនចេះស្គាល់គ្នាទេ មិនចេះរស់នៅដោយសុខដុមទេ ហើយជាធម្មតា គេរស់នៅក្នុងភាពភ័យភិតនិងភាពអស់សង្ឃឹម។

វីរបុរសកាន់ចន្លុះ គឺព្រះពុទ្ធដំណែងខ្លួនជាមនុស្សលោកចុះមកបំភ្លឺពិភពលោកដោយប្រាជ្ញាញាណ និងសេចក្ដីអាសូររបស់ព្រះអង្គ។

មនុស្សលោកដែលត្រូវបានបំភ្លឺដោយពន្លឺនេះ អាចមើលឃើញខ្លួនឯងល្អដូចគេឯទៀតដែរ ហើយកើតមានចិត្តសប្បាយរីករាយក្នុងការបង្កើតសហគមន៍ និងការទាក់ទងគ្នាដោយ

ភាពសុខដុម។

មនុស្សរាប់លាននាក់អាចរស់នៅជាមួយគ្នាបាន តែគេមិនអាចរួបរួមគ្នាជាសហគមន៍បានទេ ដរាបណាគេមិនស្គាល់គ្នាទៅវិញទៅមកដោយសមានចិត្ត។

នៅក្នុងសហគមន៍ពិតប្រាកដ តែងតែមានពន្លឺនៃជំនឿទុកចិត្តនិងគតិបណ្ឌិត ចែងចាំងព្រោងព្រាយ។ សហគមន៍ពិតប្រាកដជាទីកន្លែងដែលជនទាំងឡាយចេះស្គាល់គ្នា ជឿទុកចិត្តគ្នាទៅវិញទៅមក ហើយរស់នៅជាមួយគ្នាដោយសុខដុម។

ភាពសុខដុម គឺជាជីវិត ជាគោលបំណងពិតនៃសហគមន៍ពិតប្រាកដទាំងឡាយ។

2. មានសហគមន៍បីប្រភេទ គឺ: ទី១ សហគមន៍ដែលកើតឡើងដោយអានុភាពទ្រព្យសម្បត្តិ ឬអំណាចនៃមេកើយធំ។

ទី២ គឺក្រុមបក្សដែលបង្កើតឡើងដោយបុគ្គលមានភាពត្រូវគ្នា។ ក្រុមបក្សរបៀបនេះអាចគង់វង្សបាន ដរាបណាសមាជិកទាំងអស់យល់ព្រមចិត្តគ្នាទៅវិញទៅមក ហើយមិនឈ្លោះប្រកែកគ្នា។

ទី៣ គឺសហគមន៍ដែលកកើតឡើងអំពីសិក្ខាបទល្អ សហ-គមន៍ដែលយកភាពសុខដុមជាគោលការណ៍ សម្រាប់គង់នៅបិតថេរ។

ប្រាកដណាស់ ក្នុងចំណោមក្រុមបក្ស ទាំងបីប្រភេទនេះ មានតែក្រុមបក្សប្រភេទទី៣ទេ ដែលពិតប្រាកដ។ សមាជិកទាំងអស់នៃក្រុមបក្សប្រភេទនេះ រស់នៅដោយមានចិត្តដូចគ្នា។ ការចេះរស់នៅដោយមានចិត្តស្របគ្នានេះ បណ្តាលឲ្យភាពស្រុះស្រួលគ្នា និងគុណធម៌គ្រប់ចំពូក បានរីកលូតលាស់ ហើយសេចក្តីសុខ សេចក្តីសប្បាយ សេចក្តីពេញចិត្ត សុក-មង្គល ក៏នឹងអាចកើតឡើងបានទៅតាមនោះ។

ពន្លឺត្រាស់ដឹងពេញលេញ ប្រដូចបានទៅនឹងទឹកភ្លៀង ដែលធ្លាក់លើកំពូលភ្នំ បង្កើតបានជាអូរ ជាស្ទឹង រួចហើយជាទន្លេធំ ហូរធ្លាក់ទៅក្នុងមហាសមុទ្រនៅទីបំផុត។

ភ្លៀងនៃព្រះសាសនាជាទីគោរពបូជា ធ្លាក់សាយទៅលើមនុស្សលោកទាំងអស់ នៅគ្រប់ស្ថានភាព និងគ្រប់កាលៈទេសៈ។ អ្នកដែលជឿតាមព្រះសាសនា រួបរួមផ្តុំគ្នាជាក្រុមតូចៗ ជាសមាគម ជាសហគមន៍ ហើយនៅទីបំផុត គេទៅជួបជុំគ្នានៅក្នុងមហាសមុទ្រនៃពន្លឺត្រាស់ដឹងពេញលេញ។

ចិត្តរបស់អ្នកទាំងនោះ រលាយចូលគ្នា ដូចទឹកដោះនឹងទឹកសុទ្ធ ដើម្បីផ្តុំគ្នាជាសហគមន៍ប្រកបដោយភាពសុខដុម។

ដូច្នេះ សិក្ខាបទពិតប្រាកដជាគ្រឹះសំខាន់នៃសហគមន៍ល្អឥតខ្ចោះ ជាពន្លឺបណ្តាលឲ្យមនុស្សទាំងឡាយ ចេះស្គាល់គ្នាទៅវិញទៅមក ចេះសម្រុះសម្រួលគ្នាទៅវិញទៅមក ចេះបំបាត់សេចក្តីគ្រោតគ្រាតនៃចិត្ត។

ដូច្នេះ អង្គការដែលកើតឡើងដោយសិក្ខាបទល្អវិសេសរបស់ព្រះពុទ្ធ អាចហៅបានថា សហគមន៍ព្រះសង្ឃ។

សមាជិកទាំងឡាយនៃពុទ្ធិកសហគមន៍ ត្រូវជួយជម្រុញគ្នាទៅវិញទៅមក ឲ្យគោរពប្រតិបត្តិសិក្ខាបទល្អនេះ ហើយខំហាត់ហ្វឹកហ្វឺនចិត្តទៅតាមនោះ។ ដូច្នេះ ពុទ្ធិកសហគមន៍ដែលអ្នកណាក៏ដោយក៏អាចចូលបានដែរនោះ តាមពិត មានតែអ្នកមានជំនឿដូចគ្នាទេ ដែលជាសមាជិក។

3. នៅក្នុងពុទ្ធិកសហគមន៍ មានសមាជិកពីរប្រភេទ គឺៈ អ្នកបង្រៀន ហើយនិងអ្នកផ្គត់ផ្គង់អ្នកបង្រៀន។ សមាជិកទាំងពីរប្រភេទនេះ ត្រូវរួបរួមគ្នា ខិតខំផ្សាយនិងថែរក្សាសាសនាឲ្យ

បាននៅឋិតថេរ។

ដូច្នេះ ដើម្បីឲ្យសហគមន៍បានល្អពេញលេញ ភាពសុខដុមត្រូវតែមានជាចាំបាច់នៅក្នុងចំណោមសមាជិកទាំងអស់។ អ្នកបង្រៀនត្រូវប្រៀនប្រដៅសមាជិក សមាជិកត្រូវគោរពអ្នកបង្រៀន ដើម្បីឲ្យមានភាពសុខដុមរវាងគ្នានឹងគ្នា។

សមាជិកទាំងឡាយនៃសហគមន៍របស់ព្រះពុទ្ធ ត្រូវជួបជុំគ្នាដោយមិត្តភាព ត្រូវមានចិត្តចង់រស់នៅជាមួយគ្នា ដោយសុខសាន្ត ហើយប្រាថ្នាឲ្យបានចិត្តស្រុះស្រួលគ្នាជាឯកភាព។

4. មានកិច្ចប្រាំមួយប្រការ ដែលនាំឲ្យសហគមន៍បានប្រកបនូវភាពសុខដុម គឺៈ ទី១ វាចាស្មោះត្រង់ ទី២ អំពើស្មោះត្រង់និងគួរសម ទី៣ ចិត្តស្មោះត្រង់និងសប្បុរស ទី៤ ការចេះចែករំលែកទ្រព្យសម្បត្តិរួមឲ្យបានស្មើភាពគ្នា ទី៥ ការចេះប្រតិបត្តិតាមសិក្ខាបទល្អបរិសុទ្ធដូចគ្នា ទី៦ ចេះមានការពិចារណាត្រឹមត្រូវ។

ក្នុងចំណោមប្រការទាំងនេះ ប្រការទី៦ ពោលគឺ ការចេះពិចារណាត្រឹមត្រូវ ជាស្នូល ដែលមានប្រការទាំងប្រាំឯទៀត

នៅព័ទ្ធជុំវិញ។

មានច្បាប់វិន័យពីរពួក មួយពួកៗមាន វិន័យប្រាំពីរដែលត្រូវប្រតិបត្តិ ដើម្បីជោគជ័យនៃសហគមន៍។ វិន័យក្នុងពួកទី១ សម្រាប់ទាំងអស់គ្នាប្រព្រឹត្តតាម គឺ:

១-ជួបជុំគ្នាឲ្យបានញឹកញាប់ ដើម្បីស្តាប់ការប្រៀនប្រដៅ ហើយពិភាក្សាគ្នា។

២-រួបរួមគ្នាដោយសេរី ហើយគោរពគ្នា ទៅវិញទៅមក។

៣-គោរពព្រះសាសនាទាំងអស់គ្នា គោរពវិន័យទាំងអស់គ្នា ហើយមិនកែប្រែវិន័យទាំងនោះ។

៤-សមាជិកចំណាស់ និងសមាជិកក្មេង ត្រូវទុកដាក់គ្នាដោយគួរសម។

៥-ត្រូវមានសេចក្តីស្មោះត្រង់ និងសេចក្តីគោរពនៅក្នុងចិត្ត។

៦-ត្រូវធ្វើចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ នៅក្នុងទីសុខស្ងប់ ហើយត្រូវលះបង់សេចក្តីសុខស្ងប់នេះឲ្យដល់អ្នកឯទៀត មុននឹងយកជារបស់ផ្ទាល់ខ្លួន។

៧-ត្រូវស្រឡាញ់មនុស្សទាំងអស់ ដោយមិនរើសមុខ ត្រូវទទួលភ្ញៀវដោយរាក់ទាក់ ត្រូវថែទាំអ្នកជំងឺដោយថ្នមថ្នាក់។ សហគមន៍ដែលគោរពប្រតិបត្តិវិន័យទាំងប្រាំពីរនេះ មិនរលំដាដាច់ខាត។

វិន័យក្នុងពួកទី២ សម្រាប់ឲ្យបុគ្គលម្នាក់ៗ ធ្វើតាម។ បុគ្គលម្នាក់ៗត្រូវ: ទី១ រក្សាចិត្តឲ្យបរិសុទ្ធ ហើយមិនទាមទារចង់បានរបស់ច្រើនហួសហេតុ ទី២ រក្សាបូរណភាព ហើយបំបាត់ចោលគ្រប់ការលោភលន់ ទី៣ មានសេចក្តីអំណត់ ហើយមិនរករឿងឈ្លោះប្រកែក ទី៤ រក្សាការស្ងៀមស្ងាត់ ហើយមិននិយាយច្រើនឥតប្រយោជន៍ ទី៥ គោរពប្រតិបត្តិច្បាប់វិន័យ ហើយមិនបំពានលើ ទី៦ រក្សាចិត្តជាសមភាព ហើយមិនគោរពតាមសិក្ខាបទដទៃទៀត ទី៧ ចេះសំចៃត្បិតត្បៀតក្នុងជីវិតរស់នៅជារៀងរាល់ថ្ងៃ។ បើសមាជិកទាំងឡាយ ធ្វើតាមវិន័យទាំងប្រាំពីរនេះ សហគមន៍នឹងបានឋិតថេរ មិនរលំដាដាច់ខាត។

5. ដូចបានអធិប្បាយពីខាងលើមកហើយថា សហគមន៍ត្រូវ

រក្សាភាពសុខដុម ទុកជាវិន័យគ្រឹះ។ ដូច្នេះ បុគ្គលណាមិនរក្សាភាពសុខដុមទេ មិនអាចហៅថាសមាជិកនៃសហគមន៍ទេ។ សមាជិកម្នាក់ៗ ត្រូវប្រយ័ត្នកុំឲ្យមានការទាស់ទែងបែកបាក់គ្នា។ បើមានការទាស់ទែងគ្នាកើតឡើង ត្រូវតែបំបាត់វាជាបន្ទាន់ ពីព្រោះការទាស់ទែងគ្នានេះនឹងបំផ្លាញសហគមន៍ទាំងមូលយ៉ាងឆាប់រហ័ស ។

ស្នាមប្រឡាក់ឈាម មិនអាចបំបាត់បាន ដោយយកឈាមទៅបន្ថែមពីលើទេ។ ការស្អប់ មិនអាចបំបាត់បានដោយយកការស្អប់ទៅបន្ថែមពីលើទេ។ ការស្អប់អាចបំបាត់បានដោយសារការបំភ្លេចវាចោល។

6. ក្នុងសម័យមួយនោះ មានស្ដេចមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទ**វិបត្តិភ័យ**។ ប្រទេសព្រះអង្គ ត្រូវបានរងសង្គ្រាមឈ្លានពានពីស្ដេចស្រឡាញ់សង្គ្រាមមួយព្រះអង្គ ព្រះនាមព្រះបាទ**ព្រហ្មទត្ត**។ ក្រោយពីនាំព្រះអគ្គមហេសី និងព្រះរាជបុត្ររត់គេចបន្តិចមក ព្រះបាទ**វិបត្តិភ័យ** ត្រូវគេចាប់បាន។ តែសំណាងល្អ ព្រះអង្គម្ចាស់ជាកូនរត់គេចរួច។

ព្រះរាជបុត្រ រកមធ្យោបាយដើម្បីរំដោះព្រះបិតាពុំបានសោះ។ នៅថ្ងៃគេពិឃាតព្រះបិតា ព្រះរាជបុត្របន្លំខ្លួនចូលទៅក្នុងទីលានពិឃាត តែមិនអាចធ្វើអ្វីកើតក្រៅពីឈរមើលគេពិឃាតព្រះបិតាកំសត់ ដោយក្ដីអស់សង្ឃឹម។

ស្ដេចឪពុកឃើញកូននៅក្នុងហ្វូងមនុស្ស ក៏និយាយខ្សឹបៗតែម្នាក់ឯងថា: «កុំស្វែងរកយូរពេល! កុំប្រព្រឹត្តដោយប្រញាប់ប្រញាល់! ទោសៈ អាចស្ងប់ទៅវិញបាន ដោយសារការបំភ្លេចវាចោល តែមួយមុខគត់!»។

ថ្ងៃជាបន្តៗមក ស្ដេចកូនខិតខំរកមធ្យោបាយសងសឹកមិនដែលលស់ពេលណាទេ។ នៅទីបំផុត ស្ដេចកូនបានចូលទៅបម្រើព្រះបាទ**ព្រហ្មទត្ត** ជាសេនាមាត្យ ហើយបានជាទីសំណប់នៃព្រះមហាក្សត្រ។

ថ្ងៃមួយ ស្ដេចកូនហែស្ដេចទៅបរបាញ់សត្វ ស្ដេចកូនរកឱកាសនឹងសងសឹក។ ស្ដេចកូនបានបញ្ឆោតនាំស្ដេចឲ្យយាងទៅកន្លែងស្ងាត់ ឆ្ងាយពីគេឯង។ នៅទីនោះ ដោយអស់កម្លាំងពេក ស្ដេចក៏ផ្ទំកើយព្រះកេសាលើភ្លៅព្រះអង្គម្ចាស់លង់លក់ទៅ ដោយទុកព្រះទ័យទាំងស្រុងលើព្រះអង្គម្ចាស់។

ព្រះអង្គម្ចាស់ដកដាវ ក្នុងបំពង់កស្តេច តែពុំដាច់ចិត្តចាក់ស្តេចសោះ។ ពាក្យបណ្តាំដែលស្តេចឪពុកឱ្យប្រាប់ នៅពេលហៀបមរណៈ ត្រូវបានរំលឹកនឹកឃើញជាថ្មីនៅក្នុងចិត្តរបស់ព្រះអង្គ។ ព្រះអង្គបានល្បងលើកដាវចាក់ស្តេចជាច្រើនដង តែព្រះអង្គមិនអាចសម្រេចព្រះទ័យសម្លាប់ស្តេចបាន។ ភ្លាមនោះ ស្តេចតើនឡើង ហើយនិទានរឿងយល់សប្តិអាក្រក់ថា ឃើញបុត្រព្រះបាទ**វិបត្តិភ័យ**ប៉ុនប៉ងនឹងសម្លាប់ព្រះអង្គប្រាប់ទៅព្រះអង្គម្ចាស់។

ព្រះអង្គម្ចាស់លើកដាវក្នុងកស្តេច បញ្ជាក់ប្រាប់ថា ព្រះអង្គជាបុត្រព្រះបាទ**វិបត្តិភ័យ** ហើយប្រកាសថាពេលវេលាត្រូវសងសឹកឲ្យព្រះបិតាមកដល់ហើយ តែព្រះអង្គសម្រេចកិច្ចនេះមិនរួច។ ព្រះអង្គម្ចាស់ ក៏បោះដាវចោលភ្លាមទៅ ហើយលុតជង្គង់ក្រាបប្របនឹងព្រះបាទាស្តេច។

នៅពេលដែលស្តេចបានជ្រាបរឿងរបស់ព្រះអង្គម្ចាស់ និងវាចាចុងក្រោយរបស់ស្តេចឪពុក ព្រះអង្គមានព្រះទ័យរំជើបរំជួលជាខ្លាំង ហើយសុំទោសព្រះអង្គម្ចាស់។ ក្រោយមកព្រះបាទ**ព្រហ្មទត្ត** ក៏ប្រគល់ប្រទេសទៅឲ្យព្រះអង្គម្ចាស់នោះ

វិញ ហើយប្រទេសទាំងពីរក៏ចងមិត្តនឹងគ្នារហូតទៅ។

ពាក្យបណ្តាំរបស់ព្រះបាទ**វិបត្តិភ័យ** នៅពេលហៀបមរណៈ «កុំស្វែងរកយូរពេល» បានន័យថា កុំចងគំនុំយូរ។ «កុំប្រព្រឹត្តដោយប្រញាប់ប្រញាល់» បានន័យថា ចំណងមិត្តភាពមិនត្រូវកាត់ផ្តាច់ភ្លាមៗទេ។

ទោសៈ មិនអាចបំពេញបាន ដោយទោសៈទេ។ ទោសៈ អាចបំបាត់បាន ដោយសារការបំភ្លេចវាចោលតែមួយមុខគត់។

សមាជិកទាំងឡាយនៃសហគមន៍ដែលយកភាពសុខដុមនៃសិក្ខាបទពិតប្រាកដជាគ្រឹះ នឹងអាចស្គាល់តម្លៃនៃរឿងនិទាននេះជានិច្ច។

មិនត្រឹមតែសមាជិកទាំងឡាយនៃសហគមន៍ទេ មនុស្សលោកទូទៅ ក៏ត្រូវតែស្គាល់តម្លៃនៃរឿងនិទាននេះ ហើយប្រតិបត្តិតាម កុំបីឃ្លៀងឃ្លាតដែរ។

II

# ដែនដីព្រះពុទ្ធ

1. ដូចបានអធិប្បាយពន្យល់ពីលើមកហើយ សហគមន៍ណា

មិនភ្លេចករណីយកិច្ចរបស់ខ្លួនគឺ ខំផ្សាយព្រះសាសនា ហើយចេះរស់នៅរួបរួមគ្នាក្នុងភាពសុខដុម សហគមន៍នោះនឹងបានរីកធំឡើងៗជាលំដាប់ ហើយព្រះសាសនា ក៏រឹតតែរីកសាយទូលំទូលាយទៅតាមនោះ។

សេចក្តីនេះបានន័យថា ចំនួនអ្នកស្វែងរកពន្លឺត្រាស់ដឹងនឹងកើនឡើងជាពន្លឹក។ ម្យ៉ាងទៀតបានន័យថា ទ័ពបិសាចចង្រៃនៃសេចក្តីលោភលន់ សេចក្តីខឹងក្រោធ សេចក្តីឆ្កួតលេលា ដែលមានសេចក្តីល្ងង់ខ្លៅនឹងតណ្ហាទាំងឡាយជាអ្នកដឹកនាំ នឹងចាប់ដកខ្លួនថយចេញ ហើយគតិបណ្ឌិត ពន្លឺ ជំនឿសេចក្តីសប្បាយរីករាយ នឹងចូលមកគ្រប់គ្រងជំនួស។

ដែនដីបិសាច ពោរពេញទៅដោយសេចក្តីលោភលន់ ទៅដោយភាពងងឹត ទៅដោយការប្រយុទ្ធ ទៅដោយសង្គ្រាម ទៅដោយដាវលំពែង ទៅដោយការបង្ហូរឈាម។ ដែនដីបិសាចពោរពេញទៅដោយការច្រណែននិន្ទាគ្នា ទៅដោយបុរេនិច្ច័យ ទៅដោយទោសៈ ទៅដោយការបោកបញ្ឆោតគ្នា ទៅដោយការបញ្ឆោរគ្នា ទៅដោយការលោក់លៀមគ្នា ទៅដោយការជេរប្រមាថគ្នា។

ប៉ុន្តែ បើពន្លឺនៃគតិធម៌ចាប់ចែងចាំងរស្មីលើដែនដីនោះ ហើយភ្លៀងនៃធម៌មេត្តាចាប់បង្អុរធ្លាក់ទៅលើដែនដីនោះ បើជំនឿចំពោះព្រះសាសនាចាប់ចាក់ឫស ដុះរីកបានជាផ្កានៃសេចក្តីសប្បាយរីករាយហើយ ដែនដីបិសាចនោះ នឹងបានទៅជាដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ។

ដូចជាខ្យល់រំហើយចាប់ធ្លាក់ ផ្កាចាប់រីក ប្រកាសប្រាប់ថារដូវផ្ការីកជិតមកដល់ហើយដូច្នោះដែរ កាលណាបុគ្គលបានសម្រេចពន្លឺត្រាស់ដឹង រុក្ខាលតាវល្លិ ភ្នំ ស្ទឹងទន្លេ និងគ្រប់វត្ថុទាំងឡាយ ដែលនៅជុំវិញបុគ្គលនោះ នឹងចាប់កម្រើករំពើកក្នុងជីវិតថ្មីមួយទៀត។

បើចិត្តបុគ្គលបានបរិសុទ្ធ អ្វីៗទាំងអស់ដែលនៅជុំវិញគេក៏ទៅជាបរិសុទ្ធដែរ។

2. កន្លែងណាដែលមានសិក្ខាបទពិតប្រាកដ ជនទាំងអស់ដែលរស់នៅកន្លែងនោះ នឹងមានចិត្តបរិសុទ្ធស្ងប់។ ជាការពិតសេចក្តីមេត្តាអាសូររបស់ព្រះពុទ្ធ ផ្តល់គុណប្រយោជន៍ទៅមនុស្សលោកទាំងអស់មិនចេះឈប់ឈរទេ ហើយរស្មីនៃសេចក្តី

មេត្តាអាសូរនោះ នឹងបំបាត់មន្ទិលទាំងអស់ពីក្នុងចិត្ត។

មិនយូរប៉ុន្មាន ចិត្តបរិសុទ្ធនឹងទៅជាចិត្តជ្រៅ ចិត្តដែលដើរតាមផ្លូវព្រះធម៌ខ្ពង់ខ្ពស់ ចិត្តស្រឡាញ់ការធ្វើទានកុសល ចិត្តស្រឡាញ់ការប្រតិបត្តិសិក្ខាបទល្អ ចិត្តអំណត់ ចិត្តទៀងទាត់ ចិត្តស្ងប់ ចិត្តប្រកបដោយគតិបណ្ឌិត ចិត្តប្រកបដោយមេត្តាធម៌ ចិត្តដែលដឹកនាំសត្វលោកទាំងឡាយ ឆ្ពោះទៅកាន់ពន្លឺត្រាស់ដឹង តាមគ្រប់មធ្យោបាយត្រឹមត្រូវ។ យ៉ាងនេះហើយដែលដែនដីព្រះពុទ្ធ ត្រូវបានកសាងឡើង។

យ៉ាងដូច្នេះឯង គ្រួសារដែលមានតែប្ដីប្រពន្ធ និងបុត្រធីតា នឹងបានទៅជាគ្រួសារមួយដែលមានព្រះពុទ្ធនៅជាមួយ។ ដូចគ្នានេះ ប្រទេសដែលរងទុក្ខដោយសារការប្រកាន់វណ្ណៈសង្គម នឹងបានទៅជាសហគមន៍មួយ ដែលមនុស្សទាំងឡាយមានចិត្តជាបងប្អូន។

ទោះជាប្រាសាទមាសក៏ដោយ បើវាប្រឡាក់ទៅដោយឈាម វាមិនអាចជាទីលំនៅរបស់ព្រះពុទ្ធបានទេ។ ផ្ទុយទៅវិញ ខ្ទមតូចមួយដែលមានពន្លឺព្រះចន្ទចាំងចូលតាមដំបូលធ្លុះធ្លាយ ក៏នឹងអាចទៅជាទីលំនៅរបស់ព្រះពុទ្ធបាន បើចិត្តរបស់

អ្នកទាំងឡាយនៅក្នុងខ្ទមនោះបរិសុទ្ធ ។

បើដែនដីព្រះពុទ្ធត្រូវបានកសាងឡើងនៅក្នុងចិត្តបរិសុទ្ធនៃបុគ្គលតែម្នាក់គត់ ចិត្តបរិសិទ្ធនោះនឹងទាក់ទាញចិត្តនៃបុគ្គលឯទៀតឲ្យចងសម្ពន្ធគ្នាជាសហគមន៍សុខដុម។ ជំនឿលើព្រះពុទ្ធ សាយចេញពីបុគ្គលម្នាក់ទៅដល់គ្រួសារ ពីគ្រួសារមួយទៅដល់ភូមិ ពីភូមិមួយទៅដល់ស្រុក ដល់ខេត្ត ដល់ក្រុង ដល់ប្រទេស ហើយនៅទីបំផុត ដល់ពិភពលោកទាំងមូល។

ជាការពិតប្រាកដណាស់ ដើម្បីផ្សាយពង្រីកព្រះសាសនាគ្មានអ្វីក្រៅពីខំពង្រីកដែនដីព្រះពុទ្ធនេះទេ។

3. លោកនេះ ដែលពោរពេញទៅដោយសេចក្ដីលោភលន់ទៅដោយអយុត្តិធម៌ ទៅដោយថ្កុកឈាម មើលទៅហាក់ដូចជាដែនដីបិសាច។ ប៉ុន្តែបើកាលណា ហើយមនុស្សទាំងឡាយជឿទុកចិត្តលើពន្លឺត្រាស់ញាណរបស់ព្រះពុទ្ធ ឈាមនោះនឹងប្រែក្លាយទៅជាទឹកដោះ សេចក្ដីលោភលន់នឹងប្រែក្លាយទៅជាមេត្តាធម៌ ហើយដែនដីបិសាចនោះនឹងប្រែក្លាយជាដែនដីព្រះពុទ្ធ។

ធ្វើឲ្យសមុទ្ររីងដោយយកស្លាបព្រាតូចមួយ ទៅដួសទឹកចេញ ដូចជាធ្វើមិនកើត ប៉ុន្តែបើគេសម្រេចចិត្តត្រូវតែធ្វើ ទោះបីត្រូវអស់រាប់រយជាតិក៏ដោយ នោះគឺជាចិត្តសម្រេចទទួលយកនូវពន្លឺត្រាស់ញាណរបស់ព្រះពុទ្ធ។

ព្រះពុទ្ធនៅវង់ចាំឯត្រើយនាយ ដែលជាដែនដីនៃពន្លឺត្រាស់ដឹង។ នៅទីនោះ គ្មានសេចក្តីលោភលន់ គ្មានសេចក្តីខឹងក្រោធ គ្មានសេចក្តីល្ងង់ខ្លៅ គ្មានទុក្ខព្រួយ គ្មានភ័យអាសន្ន មានតែពន្លឺនៃគតិធម៌ និងភ្លៀងនៃសេចក្តីមេត្តាអាសូរ។

ទីនោះ ជាឋានប្រកបដោយសុខសន្តិភាព ជាជម្រកសម្រាប់អ្នកមានទុក្ខ មានព្រួយ មានភ័យអាសន្ន ជាកន្លែងឈប់សម្រាករបស់អ្នកផ្សាយព្រះសាសនា។

នៅក្នុងដែនដីបរិសុទ្ធនោះ ពន្លឺចែងចាំងគ្រប់ទិសទី ជីវិតឋិតថេររហូត។ អ្នកដែលបានទៅដល់ឋានសុខស្ងប់នោះ នឹងមិនវិលត្រឡប់មកឋាន ដែលពោរពេញទៅដោយរឿងថ្លឹងថ្លែងនេះវិញទេ។

ដោយពិត ឋានបរិសុទ្ធនោះ ដែលមានផ្កាគ្រប់ពណ៌ផ្សព្វផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់នៃគតិធម៌ មានសត្វបក្សីល្អៗ

ប្រគំបទចម្រៀងព្រះធម៌យ៉ាងពីរោះលន្លោច ជាទីត្រេកត្រអាល
ទីបំផុត សម្រាប់សត្វលោកទាំងអស់។

4. ឋានបរិសុទ្ធនោះជាកន្លែងសម្រាកកម្លាំង ក៏ពិតហើយ តែមិនមែនជាកន្លែងសម្រាប់ការខ្ជិលច្រអូសទេ។ គុម្ពោតផ្កាក្រអូបឈ្ងុយឈ្ងប់ ពុំមែនសម្រាប់ភាពព្រងើយកន្តើយទេ គឺសម្រាប់សម្រាកកាយ ដើម្បីឲ្យមានកម្លាំងវៀសវៃជាថ្មីឡើងវិញ ដើម្បីនឹងបន្តបេសកកម្មព្រះពុទ្ធតទៅទៀត។

បេសកកម្មព្រះពុទ្ធ មិនចេះចប់ទេ។ ដរាបណា សត្វលោកនៅមានជីវិតរស់នៅ ហើយចិត្តអត្តទត្ថៈ ពោរពេញទៅដោយអំពើពុករលួយនៅតែមាន បេសកកម្មនេះ នឹងមិនចប់ជាដាច់ខាត។

កូនចៅព្រះពុទ្ធ ដែលបានទៅដល់ត្រើយនាយនៃដែនដីបរិសុទ្ធដោយសារមហាអនុភាពនៃព្រះពុទ្ធ**អាមិដា** នឹងបានទទួលកម្លាំងវៀសវៃគ្រប់គ្រាន់ ដើម្បីត្រឡប់មកជួយធ្វើបេសកកម្មរបស់ព្រះពុទ្ធ នៅក្នុងលោកនេះវិញ ។

ពន្លឺនៃទៀនតែមួយដើមគត់អាចបន្តទៅទៀនឯទៀតជា

បន្តបន្ទាប់បានយ៉ាងណា ពន្លឺនៃធម៌មេត្តារបស់ព្រះពុទ្ធក៏អាច បន្តពីដួងចិត្តមួយទៅដួងចិត្តមួយ ជាបន្តបន្ទាប់ គ្មានទីបញ្ចប់ យ៉ាងនោះដែរ។

ដោយមានចិត្តប្រកបដោយមេត្តាធម៌ កូនចៅព្រះពុទ្ធ ទទួលធ្វើកិច្ចការសម្រាប់សេចក្តីត្រាស់ដឹង និងសេចក្តីបរិសុទ្ធ របស់ព្រះអង្គ ហើយបន្តកិច្ចការនោះរៀងរហូត ពីជំនាន់មួយ ទៅជំនាន់មួយ ដើម្បីឲ្យដែនដីព្រះពុទ្ធបានជាឋានប្រសើរ ជានិច្ចតរៀងទៅ។

III

# អ្នកទ្រទ្រង់ដែនដីព្រះពុទ្ធ

1. ព្រះនាង **សាមាវតី** មហេសីទីមួយនៃព្រះបាទ **ឧទេន** ទ្រង់មានភក្តីភាពយ៉ាងជ្រាលជ្រៅចំពោះព្រះពុទ្ធ។

ព្រះនាងគង់នៅក្នុងប្រាសាទមួយដាច់ស្រយាលឆ្ងាយពីគេនៅក្នុងទីខាងក្នុងបំផុតនៃព្រះបរមរាជវាំង។ នាងគមដែលជាភិលៀងជំនិតរបស់ព្រះនាង ជាស្រីមានស្មារតីពូកែចាំអស្ចារ្យ។

នាងគម តែងតែចេញទៅស្តាប់ព្រះធម្មទេសនា របស់ព្រះពុទ្ធជាម្ចាស់ហើយយកមកនិទានថ្វាយព្រះអគ្គមហេសី ជាទីសណ្តាប់ៗ ដូច្នេះ ព្រះអគ្គមហេសីរឹតតែមានសតិប្រាជ្ញាខ្ពង់ខ្ពស់នឹងជំនឿមុតមាំ កាន់តែជ្រៅឡើងៗ។

មហេសីទីពីរ មានសេចក្តីច្រណែននឹងព្រះនាង ក៏រកឧបាយកលសម្លាប់ព្រះនាង។ មហេសីទីពីររករឿងគ្រប់បែបយ៉ាង ទូលញុះញង់ស្តេច រហូតដល់ស្តេចជឿតាម ហើយបញ្ជាឲ្យសម្លាប់ព្រះនាង **សាមាវតី** មហេសីទីមួយរបស់ព្រះអង្គ។

ព្រះនាង **សាមាវតី** ទ្រង់គង់នៅយ៉ាងស្ងៀមស្ងាត់គ្មានព្រះបន្ទូលមួយម៉ាត់តបតនឹងព្រះមហាក្សត្រ រហូតដល់ស្តេចអស់មានចិត្តនឹងប្រហារព្រះនាង។ ព្រះមហាក្សត្រក៏បានស្ងប់ព្រះចិន្តាឡើងវិញ ហើយសុំទោសព្រះនាង ចំពោះការដែលព្រះអង្គមិនទុកចិត្តនឹងព្រះនាង។

សេចក្តីច្រណែននិន្ទានៃព្រះមហេសីទីពីរ កាន់តែរីកធំឡើងៗ ជាលំដាប់។ ព្រះមហេសីទីពីរ ទ្រង់បញ្ជូនអ្នកលេងកាប់ចាក់ឲ្យទៅដុតចុងជាយវាំង នៅពេលស្តេចមិននៅ។ ព្រះនាង **សាមាវតី** ទ្រង់រក្សាសេចក្តីស្ងប់ជានិច្ច លួងលោមលើក

ទឹកចិត្តស្រីបម្រើទាំងឡាយដែលភិតភ័យ។ រួចហើយព្រះនាងទ្រង់សុគតទៅដោយឥតតក់ស្លុត ដោយចិត្តស្ងប់ទៅតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធជាម្ចាស់។ នាងគម **ឧត្តរា** ក៏ស្លាប់នៅក្នុងភ្លើងជាមួយនឹងព្រះនាង ក្នុងពេលនោះដែរ។

ក្នុងចំណោមស្រីជាឧបាសិការបស់ព្រះពុទ្ធ ស្រីទាំងពីរនេះ ជាទីគោរពបូជាប្រសើរជាគេបង្អស់ គឺៈព្រះនាង**សាមាវតី** ជាស្រីមានចិត្តប្រកបដោយសេចក្តីមេត្តាធម៌ នាងគមជាស្រីប្រកបដោយគតិធម៌ ។

2. ព្រះបាទ **មហានាម** ក្នុងវង្សសក្យ ត្រូវជាបងប្អូនជីដូនមួយនឹងព្រះពុទ្ធ ទ្រង់មានជំនឿជ្រាលជ្រៅក្នុងព្រះសាសនា ហើយជាសាវ័កស្មោះត្រង់ជាងគេមួយព្រះអង្គ។

ថ្ងៃមួយ ស្តេចឃោរឃៅនៃនគរ**កោសល** ព្រះនាម**វិរុឡ្ហក** ចូលមកច្បាំងដណ្តើមយកនគរ**សក្យ**។ ព្រះបាទ**មហានាម** យាងចេញទៅក្រាបបង្គំទូលស្តេចឃោរឃៅនោះ សុំឲ្យទុកជីវិតឲ្យប្រជារាស្ត្រព្រះអង្គ តែស្តេចឃោរឃៅមិនព្រមស្តាប់សេចក្តីអង្វរនេះឡើយ។ ព្រះបាទ**មហានាម** ក៏ទូលស្នើសុំឲ្យ

មហារាជ**វិរុឡ្ហក** ដោះលែងអ្នកជាប់ឃុំទាំងអស់ឲ្យរត់ចេញពីវាំងប្រាសាទ ក្នុងអំឡុងពេលដែលព្រះអង្គមុជបាត់ទៅក្នុងត្រពាំងទឹកមួយនៅជិតនោះ។

ស្តេចឃោរឃៅ ក៏យល់ព្រម ដោយជឿជាក់ថា ព្រះបាទ**មហានាម** មិនអាចទ្រាំមុជក្នុងទឹកបានយូរទេ។

នៅពេលព្រះបាទ**មហានាម** មុជនៅក្នុងទឹក ទ្វារវាំងក៏បើកឡើង ហើយអ្នកជាប់ឃុំទាំងឡាយក៏ប្រាសរត់រកព្រះអាយុរៀងខ្លួន។ ប៉ុន្តែមិនឃើញព្រះបាទ**មហានាម** ងើបចេញពីទឹកសោះ ព្រះអង្គទ្រង់បូជាជីវិតព្រះអង្គសម្រាប់ប្រជារាស្ត្រព្រះអង្គ ដោយយកសក់ទៅចងភ្ជាប់នឹងឫសឈើដែលដុះក្នុងទឹក។

3. មានដូនជីម្នាក់ឈ្មោះ ***ឧប្បលវណ្ណា*** ល្បីល្បាញមានប្រាជ្ញាស្មើនឹងព្រះមោគ្គល្លាន ដែលជាសាវ័កធំជាងគេមួយព្រះអង្គរបស់ព្រះពុទ្ធ។ នាង**ឧប្បលវណ្ណា** ពិតជាដូនជីឧត្តមមួយក្នុងពពួកដូនជីទាំងឡាយ។ នាងតែងតែដឹកនាំ បង្ហាត់បង្រៀនព្រះសាសនា ដល់ពួកដូនជីទាំងឡាយ ដោយគ្មានគិតដល់ការនឿយហត់របស់ព្រះនាងឡើយ។

***ទេវទត្ត*** *ជាបុរសឃោរឃៅអាក្រក់បំផុត។ បុរសនេះបំពុលចិត្តស្ដេច* ***អជាតសត្តុ*** *ហើយបញ្ចុះបញ្ចូលព្រះអង្គ ឲ្យប្រឆាំងនឹងសាសនាព្រះពុទ្ធ។ ក្រោយមកមហារាជ****អជាតសត្តុ*** *ទ្រង់មានសេចក្ដីស្ដាយក្រោយ ទ្រង់ផ្ដាច់ចំណងមិត្តភាព ជាមួយនឹង****ទេវទត្ត*** *ហើយព្រះអង្គបានជាសាវ័ករបស់ព្រះពុទ្ធម្នាក់។*

*ថ្ងៃមួយ* ***ទេវទត្ត****ចង់ចូលទៅជួបស្ដេច តែត្រូវអ្នកយាមទ្វារបណ្ដេញមិនឲ្យចូលវាំង។ ពេលនោះ* ***ទេវទត្ត*** *បានឃើញដូនជី* ***ឧប្បលវណ្ណា*** *ចេញពីក្នុងវាំងមក។* ***ទេវទត្ត****ខឹងណាស់ ហើយវាយដូនជីរហូតដល់មានរបួសជាទម្ងន់។*

*ដូនជី ខំប្រវេប្រវា ដើរផងវារផង ទាល់តែបានមកដល់អាស្រមវិញ ទាំងសេចក្ដីឈឺចាប់ជាខ្លាំង។ នៅពេលដែលដូនជីឯទៀតកំពុងខិតខំលួងលោមនាង ដូនជីមានវាចាថាៈ «ម្នាលដូនជីទាំងឡាយ ! ជីវិតមនុស្ស មិនអាចទាយទុកមុនបានទេ។ អ្វីៗទាំងអស់ មិនឋិតថេរទេ គ្មានខ្លឹមសារទេ។ មានតែពិភពពន្លឺត្រាស់ដឹងទេ ដែលឋិតថេរសុខស្ងប់។ ចូរបន្តជីវិតរស់នៅរបស់អ្នកក្នុងព្រះសាសនា ជាបន្តទៅទៀត កុំបីខាន»។*

មានវាចាចប់ហើយ ដូនជី **ឧប្បលវណ្ណា** ក៏រំលាយខន្ធទៅដោយសុខស្ងប់។

4. ពីដើម **អង្គុលិមាល** ជាមេចោរកាចសាហាវសម្បើមណាស់ បានកាប់សម្លាប់មនុស្សរាប់មិនអស់។ ប៉ុន្តែ ក្រោយមកព្រះពុទ្ធជាម្ចាស់បានស្រោចស្រង់មេចោរនេះ ហើយគេក៏បានទៅជាសមាជិកនៃពុទ្ធិកសហគមន៍ម្នាក់ទៅ។ ថ្ងៃមួយ ភិក្ខុអតីតមេចោរ បានចេញទៅបិណ្ឌបាតនៅក្នុងក្រុង តែភិក្ខុត្រូវបានទទួលរងនូវទារុណកម្មជាច្រើន ដោយសារអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តពីអតីតកាល។

អ្នកស្រុកនាំគ្នាវាយដំប្រំផាក់ភិក្ខុអតីតមេចោរ គ្មានមេត្តាប្រណីបន្តិចឡើយ។ ភិក្ខុអតីតមេចោរ ត្រឡប់មកវត្តវិញ ទៅលុតជង្គង់ក្រាបប្របព្រះបាទាព្រះពុទ្ធជាម្ចាស់ទាំងឈាមហូរសស្រាក់ ដើម្បីសម្ដែងសេចក្ដីដឹងគុណដល់ព្រះអង្គ ក្នុងការដែលព្រះអង្គទ្រង់បានរកឱកាសឲ្យគេទទួលទុក្ខទោសចំពោះអំពើឃោរឃៅ ដែលគេបានប្រព្រឹត្តពីមុនមក។

ភិក្ខុអតីតមេចោរ ក្រាបទូលព្រះពុទ្ធថា: «ឱព្រះជាម្ចាស់! ដើមឡើយ ឈ្មោះរបស់ខ្ញុំព្រះអង្គនេះ មិនជាអាក្រក់ទេ។ តែ

ក្រោយមក ខ្ញុំព្រះអង្គបានសម្លាប់មនុស្សអស់ជាច្រើន ហើយកាត់យកម្រាមដៃអ្នករងគ្រោះទាំងនោះសន្សំទុក ខ្ញុំព្រះអង្គ ក៏ត្រូវបានទទួលឈ្មោះថា **អង្គុលិមាល** ឬអ្នកសន្សំម្រាមដៃ តាំងពីពេលនោះមក។

«តែពេលនេះ ដោយសារសេចក្តីអាសូររបស់ព្រះជាម្ចាស់ ខ្ញុំព្រះអង្គក៏បានយល់នូវគតិធម៌ ហើយមានភក្តីភាពចំពោះរតនៈទាំងបី គឺៈ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ អ្នកដែលចង់ជិះសេះ ឬជិះគោ ត្រូវតែកាន់រំពាត់ខ្សែតីមួយ ជាចាំបាច់។ តែចំពោះព្រះជាម្ចាស់ ព្រះអង្គអាចធ្វើឲ្យខ្ញុំព្រះអង្គបានបរិសុទ្ធ ដោយគ្មានប្រើរំពាត់ខ្សែតីអ្វីឡើយ។

«ឱព្រះជាម្ចាស់ ! ថ្ងៃនេះ ខ្ញុំព្រះអង្គ បានទទួលរបស់ដែលត្រូវទទួល។ ខ្ញុំព្រះអង្គមិនចង់រស់ ប៉ុន្តែ ក៏មិនចង់ស្លាប់ដែរ។ ខ្ញុំព្រះអង្គ រង់ចាំពេលវេលា ដែលត្រូវមកដល់ខ្លួនខ្ញុំព្រះអង្គ តែប៉ុណ្ណោះ»។

5. ព្រះ**មោគ្គល្លាន** នឹងព្រះ**សារីបុត្ត** ជាសាវ័កផុតថ្នាក់របស់ព្រះពុទ្ធ។ នៅពេលដែលពួកបព្វជិតនៃសាសនាដទៃទៀតឃើញទឹកអម្រឹតបរិសុទ្ធនៃសាសនាព្រះពុទ្ធ ធ្លាក់សាយប្រោះព្រំលើ

សត្វលោក ហើយសត្វលោកទទួលផឹក ដោយអការៈស្រេកឃ្លាន ពួកបព្វជិតនៃសាសនាឯទៀតទាំងនោះ ក៏កើតមានសេចក្តីច្រណែន ហើយបង្កឧបសគ្គរឿងហេតុគ្រប់បែបយ៉ាងចំពោះសាសនាព្រះពុទ្ធ។

តែគ្មានឧបសគ្គណាមួយអាចទប់ទល់រាំងរាព្រះសាសនាកុំឲ្យរីកសាយបានឡើយ។ ដោយហេតុនេះ ពួកកាន់សាសនាដទៃទៀតនោះ ប៉ុនប៉ងនឹងសម្លាប់ព្រះ**មោគ្គល្លាន**។

ព្រះ**មោគ្គល្លាន** ទ្រង់បានគេចផុតអំពីការប៉ុនប៉ងឃោរឃៅនេះពីរលើក។ តែនៅលើកទីបី ព្រះ**មោគ្គល្លាន**ត្រូវបានពួកឃាតករជាច្រើនព័ទ្ធជាប់ ហើយធ្វើគតព្រះអង្គក្នុងពេលនោះទៅ។

ដោយមានពន្លឺត្រាស់ដឹងជួយទ្រទ្រង់ ព្រះ**មោគ្គល្លាន**ទ្រង់ទទួលរងការធ្លាក់វាយប្រហារនៃឃាតករទុរយស ដោយស្ងប់ស្ងៀម ឥតតក់ស្លុត។ សាច់របស់ព្រះអង្គ ត្រូវបានគេរះហែកជាចំណែក ឆ្អឹងរបស់ព្រះអង្គ ត្រូវបានគេកិនបំបាក់ជាកំណាត់ល្អិត តែព្រះ**មោគ្គល្លាន**គ្មានការឈឺចាប់ ព្រះអង្គទ្រង់អស់សង្ខារទៅ ដោយសុខស្ងប់។

# អង្គុត្តរនិកាយ

ម្នាលភិក្ខុទាំងឡាយ! មានបុគ្គលឯកមកកើតក្នុងលោកនេះ សម្រាប់ជាប្រយោជន៍នៃបុគ្គលជាច្រើន សម្រាប់ជាសុភមង្គលនៃបុគ្គលជាច្រើន។ បុគ្គលឯកនោះមកចាប់កំណើត ដោយសារសេចក្ដីករុណាអាសូរចំពោះលោកនេះ និងដើម្បីជាប្រយោជន៍នៃលោកនេះ ដើម្បីជាសុខុមាលភាព និងសុភមង្គលនៃទេវលោកផង និងមនុស្សលោកផង។ តើបុគ្គលឯកនោះជាអ្នកណា? ម្នាលភិក្ខុទាំងឡាយ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! មានបុគ្គលឯក ដែលមិនងាយនឹងបញ្ចេញឲ្យឃើញទេ នៅក្នុងលោកនេះ។ តើបុគ្គលឯកនោះ ជាអ្នកណា? ម្នាលភិក្ខុទាំងឡាយ ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! នៅក្នុងលោកនេះ មានបុគ្គលអស្ចារ្យម្នាក់ដែលមិនងាយនឹងបានជួបប្រទះ។ តើបុគ្គលអស្ចារ្យនោះ ជាអ្នកណា? បុគ្គលអស្ចារ្យនោះគឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! មានបុគ្គលឯក ដែលនៅពេលស្លាប់ទៅសត្វលោកទាំងអស់ស្ដាយស្រណោះ។ តើបុគ្គលឯកនោះ ជាអ្នកណា? ម្នាលភិក្ខុ ទាំងឡាយ ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! មានបុគ្គលឯកកើតក្នុងលោកនេះ ដែលគ្មានអ្នកណាម្នាក់អាចប្រៀបស្មើបាន។ តើបុគ្គលឯកនោះ ជាអ្នកណា? ម្នាលភិក្ខុទាំងឡាយ ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! មានបុគ្គលឯក ដែលចេញឲ្យឃើញប្រត្យក្សក្នុងភាពមាននេត្រាប្រកបដោយអានុភាព មានពន្លឺភ្លឺត្រចេះត្រចង់ មានរស្មីសាយចេញធំមហិមា។ តើបុគ្គលឯកនោះ ជាអ្នកណា? ម្នាលភិក្ខុទាំងឡាយ ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ -អង្គុត្តរនិកាយ ១-១៣ -

# ប្រភពដកស្រង័បញ្ជាក់

ពាក្យបំព្រួញ : ទ.ន. : ទីឃនិកាយ
ម.ន. : មជ្ឈិមនិកាយ
ស.ន. : សំយុត្តនិកាយ
អ.ន. : អង្គុត្តរនិកាយ

# ព្រះពុទ្ធ

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| **ចំពូកទី ១** | | | |
| 1 | 2 | 1 | គម្ពីរផ្សេងៗ |
| | 7 | 1 | អ.ន. ៣ - ៣៨ សុខុមាលាសូត្រ |
| | 7 | 14 | ម.ន. ៣ - ២៦ អរិយបរិយេសនសូត្រ |
| | 8 | 9 | សុត្តន្តបិដក |
| | 10 | 11 | ម.ន. ៩ - ៨៥ ពោធិរាជកុមារសូត្រ |
| | 11 | 1 | សុត្តន្តបិដក |
| | 11 | 12 | សុត្តនិបាត ៣ - ២ បធានសូត្រ |
| | 12 | 4 | គម្ពីរព្រះសូត្រផ្សេងៗ |
| | 13 | 4 | វិន័យ មហាវគ្គ ១ |
| | 15 | 5 | ទ.ន. ១៦ មហាបរិនិព្វានសូត្រ |
| 2 | 17 | 3 | ទ.ន. ១៦ មហាបរិនិព្វានសូត្រ |
| | 19 | 7 | បរិនិព្វានសូត្រ |
| | 23 | 2 | បរិនិព្វានសូត្រ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រកពជកស្រង់ |
|---|---|---|---|
| | 23 | 10 | ទ.ន. ១៦ មហាបរិនិព្វានសូត្រ |

**ចំពូកាជី ២**

| | | | |
|---|---|---|---|
| 1 | 25 | 1 | អមិតាយុរធ្យានសូត្រ វិមលកិរ្តិនិរទេសសូត្រ |
| | 25 | 6 | សូរំគមសូត្រ |
| | 26 | 1 | វិមលកិរ្តិនិរទេសសូត្រ មហាបរិនិព្វានសូត្រ |
| | 26 | 16 | សទ្ធម៌បុណ្ឌរីកសូត្រ ១៦ |
| | 28 | 2 | មហាយានជាតក ចិត្តភូមិបរិក្សសូត្រ |
| | 28 | 9 | មហាបរិនិព្វានសូត្រ |
| 2 | 31 | 14 | សទ្ធម៌បុណ្ឌរីកសូត្រ ៣ |
| | 33 | 9 | សទ្ធម៌បុណ្ឌរីកសូត្រ ៤ |
| | 36 | 1 | សទ្ធម៌បុណ្ឌរីកសូត្រ ៥ |
| 3 | 38 | 1 | សទ្ធម៌បុណ្ឌរីកសូត្រ ១៦ |

**ចំពូកាជី ៣**

| | | | |
|---|---|---|---|
| 1 | 42 | 1 | អវតំសកសូត្រ ៣ |
| | 44 | 1 | មហាបរិនិព្វានសូត្រ |
| | 44 | 8 | អវតំសកសូត្រ |
| | 45 | 1 | សុវណ៌ប្រភាសោត្តមរាជសូត្រ ៣ |
| 2 | 48 | 16 | អវតំសកសូត្រ |
| | 49 | 8 | អវតំសកសូត្រ ៣៤ គណ្ឌព្យូហៈ |
| | 49 | 13 | សុខាវតីព្យូហៈសូត្រតូច |
| | 50 | 2 | អវតំសកសូត្រ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| | 50 | 8 | ស.ន. ៣៥ - ៥ |
| | 50 | 13 | មហាបរិនិព្វានសូត្រ |
| 3 | 54 | 5 | ម.ន. ៨ - ៧៧ មហាសកុលូទយិសូត្រ |
| | 55 | 13 | មហាបរិនិព្វានសូត្រ |
| | 56 | 12 | លង្កាវតារសូត្រ |
| | 57 | 7 | អវតំសកសូត្រ ៣២ |
| | 58 | 10 | សទ្ធម៌បុណ្ឌរីកសូត្រ ២៥ |
| | 58 | 15 | មហាបរិនិព្វានសូត្រ |
| | 59 | 14 | សទ្ធម៌បុណ្ឌរីកសូត្រ ២ |
| | 60 | 6 | សទ្ធម៌បុណ្ឌរីកសូត្រ ២ |

## ព្រះធម៌

**ជំពូកទី ១**

| | | | |
|---|---|---|---|
| 1 | 64 | 1 | វិន័យ មហាវគ្គ ១-៦ ស.ន. ៥៦-១១-១២ ធម្មចក្កប្បវត្តនសូត្រ |
| | 66 | 6 | ឥតិវុត្តកៈ ១០៣ |
| | 67 | 3 | ម.ន. ២ សព្វាសវសូត្រ |
| | 67 | 10 | សូត្រ ៤២ បំពូក ១៨ |
| | 68 | 9 | ស្រីមាលាទេវីសីហនាទសូត្រ |
| 3 | 70 | 16 | អវតំសកសូត្រ ២២ ទសភូមិកៈ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| **ចំពូកទី ២** | | | |
| 1 | 76 | 1 | ម.ន. ៤ - ៣៥ ចូឡសច្ចកសូត្រ |
| | 79 | 3 | អ.ន. ៥ - ៤៩ មុណ្ឌរាជវគ្គ |
| | 79 | 15 | អ.ន. ៤ - ១៨៥ សមណសូត្រ |
| | 80 | 7 | អ.ន. ៣ - ១៣៤ ឧប្បាទសូត្រ |
| 2 | 80 | 15 | លង្ការវតារសូត្រ |
| | 81 | 3 | អវតំសកសូត្រ ២ |
| | 81 | 13 | អវតំសកសូត្រ ១៦ |
| | 82 | 10 | អវតំសកសូត្រ ២២ ទសភូមិកៈ |
| | 83 | 3 | លង្ការវតារសូត្រ |
| | 83 | 8 | អ.ន. ៤ - ១៨៦ ឧម្មគ្គសូត្រ |
| | 83 | 14 | ធម្មបទ ១, ២, ១៧, ១៨ |
| | 84 | 11 | ស.ន. ២-១-៦ កាមទសូត្រ |
| 3 | 85 | 6 | អវតំសកសូត្រ ១៦ |
| | 85 | 16 | លង្ការវតារសូត្រ |
| | 87 | 1 | ម.ន. ៣-២២ អលគទ្ទូបមសូត្រ |
| | 88 | 6 | លង្ការវតារសូត្រ |
| | 88 | 12 | លង្ការវតារសូត្រ |
| 4 | 92 | 15 | វិន័យ, មហាវគ្គ ១-៦ |
| | 93 | 14 | លង្ការវតារសូត្រ |
| | 94 | 5 | ស.ន. ៣៥-២០០ ទារុក្ខន្ធសូត្រ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| | 94 | 16 | លង្ការវតារសូត្រ និង គម្ពីរផ្សេងៗទៀត |
| | 96 | 2 | ម.ន. ២-១៨ មធុបិណ្ឌិកសូត្រ |
| | 97 | 1 | លង្ការវតារសូត្រ |
| | 98 | 1 | លង្ការវតារសូត្រ |
| | 99 | 10 | វិមលកិត្តិនិទ្ទេសសូត្រ |
| | 102 | 16 | អវតំសកសូត្រ ៣២ គណ្ឌព្យូហៈ |
| | 103 | 10 | លង្ការវតារសូត្រ និងគម្ពីរផ្សេងៗទៀត |

**ចំពូកទី ៣**

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| 1 | 105 | 1 | វិន័យ, មហាវគ្គ ១-៥ |
| | 106 | 5 | វិន័យ, ចូឡវគ្គ ៥-២១ |
| | 106 | 15 | សូរំគមសូត្រ |
| 2 | 115 | 1 | សូរំគមសូត្រ |
| | 117 | 13 | មហាបរិនិព្វានសូត្រ |
| | 118 | 5 | សទ្ធម៌បុណ្ឌរីកសូត្រ ៧ សូរំគមសូត្រ |
| | 119 | 5 | អវតំសកសូត្រ ៣២ |
| | 119 | 10 | មហាបរិនិព្វានសូត្រ |
| | 119 | 16 | ព្រហ្មជាលសូត្រ |
| | 120 | 11 | មហាបរិនិព្វានសូត្រ |
| 3 | 121 | 15 | មហាបរិនិព្វានសូត្រ |

**ចំពូកទី ៤**

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| 1 | 129 | 1 | ស្រីមាលាទេវីសីហនាទសូត្រ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| | 130 | 16 | អ.ន. ២-១១ |
| | 131 | 6 | ឥតិវុត្តក: ៩៣ |
| | 131 | 14 | វិន័យ មហាវគ្គ |
| | 132 | 10 | អ.ន. ៣-៦៨ អញ្ញាតិដ្ឋិកសូត្រ |
| | 133 | 9 | អ.ន. ៣-៣២ អាឡវកសូត្រ |
| | 134 | 10 | វេបុល្យសូត្រ |
| | 134 | 16 | វិន័យ មហាវគ្គ ១-៦ ធម្មចក្កប្បវត្តនសូត្រ |
| | 135 | 5 | ម.ន. ២-១២ ចូឡទុក្ខខន្ធសូត្រ |
| | 136 | 7 | មហាបរិនិព្វានសូត្រ |
| | 138 | 3 | ឥតិវុត្តក: ២២ |
| 2 | 140 | 11 | ម.ន. ៦-៥១ កន្ទរក:សុត្តន្ត: |
| | 141 | 13 | អ.ន. ៣-១៣០ |
| | 142 | 6 | អ.ន. ៣-១១៣ |
| 3 | 143 | 5 | ឥតិវុត្តក: ១០០ |
| | 144 | 4 | សំយុត្តវត្ថុបិដកសូត្រ |
| | 145 | 8 | មហាបរិនិព្វានសូត្រ |
| | 147 | 13 | អ.ន. ៣-៦២ |
| | 148 | 10 | អ.ន. ៣-៣៥ ទេវទូតសូត្រ |
| | 150 | 9 | ថេរីគាថា អដ្ឋកថា |
| 4 | 152 | 1 | សុខាវតីព្យូហ:សូត្រ ក្បាលទី ២ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| **ចំពូកទី ៤** | | | |
| 1 | 162 | 1 | សុខាវតីព្យូហៈសូត្រ ក្បាលទី ១ |
| | 167 | 4 | សុខាវតីព្យូហៈសូត្រ ក្បាលទី ២ |
| | 169 | 5 | អមិតាយុរធ្យានសូត្រ |
| 2 | 174 | 7 | សុខាវតីព្យូហៈសូត្រ គម្ពីរតូច |


## វត្តប្រតិបត្តិព្រះពុទ្ធសាសនា


| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| **ចំពូកទី ១** | | | |
| 1 | 180 | 1 | ម.ន.២ សព្វាសវសូត្រ |
| | 183 | 2 | ម.ន. ៣-២៦ អរិយបរិយេសនសូត្រ |
| | 184 | 3 | ស.ន. ៣៥-២០៦ ឆបានសូត្រ |
| | 185 | 14 | សូត្រ ៤២ ចំពូក ៤១-២ |
| | 189 | 11 | ម.ន. ២-១៩ ទ្វេធាវិតក្កសូត្រ |
| | 190 | 16 | ធម្មបទ អដ្ឋកថា |
| 2 | 192 | 11 | អ.ន. ៣-១១៧ |
| | 193 | 10 | ម.ន. ៣-២១ កកចូបមសូត្រ |
| | 198 | 11 | ម.ន. ៣-២៣ វម្មីកសូត្រ |
| | 201 | 3 | ជាតក ៤-៤៩៧ មាតង្គជាតក |
| | 207 | 4 | សូត្រ ៤២ ចំពូក ៩ |
| | 207 | 14 | សូត្រ ៤២ ចំពូក ១១ |
| | 209 | 14 | សូត្រ ៤២ ចំពូក ១៣ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| | 210 | 14 | អ.ន. ២-៤សមចិត្តសូត្រ |
| 3 | 212 | 1 | សំយុត្តវគ្គបិដកសូត្រ |
| | 227 | 14 | មហាបរិនិព្វានសូត្រ |
| | 229 | 2 | សំយុត្តវគ្គបិដកសូត្រ |

**ចំពូកទី ២**

| | | | |
|---|---|---|---|
| 1 | 235 | 1 | ម.ន. ៧-៦៣ ចូឡមាលុក្យសុត្តន្ត |
| | 238 | 5 | ម.ន. ៣-២៩ មហាសារោបមសូត្រ |
| | 240 | 12 | មហាមាយាសាស្ត្រា |
| | 241 | 10 | ថេរគាថា អដ្ឋកថា |
| | 244 | 9 | ម.ន. ៣-២៨ មហាហត្ថិបទោបមសូត្រ |
| | 245 | 11 | មហាបរិនិព្វានសូត្រ |
| | 246 | 8 | អវទានសតកសូត្រ |
| | 248 | 9 | មហាបរិនិព្វានសូត្រ |
| | 251 | 4 | បញ្ចវិមំសតិ សាហស្រិកា ប្រាជ្ញាបារមិតាសូត្រ |
| | 253 | 9 | អវតំសកសូត្រ ៣៤ គណ្ឌព្យូហៈ |
| 2 | 256 | 8 | អ.ន. ៣-៨៨ |
| | 257 | 14 | អ.ន. ៣-៨១ |
| | 258 | 4 | អ.ន. ៣-៨២ |
| | 259 | 3 | បរិនិព្វានសូត្រ ក្បាលទី ២ |
| | 260 | 14 | ម.ន. ១៤-១៤១ សច្ចវិភង្គសូត្រ |
| | 262 | 7 | បរិនិព្វានសូត្រ ក្បាលទី ២ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| | 263 | 5 | អ.ន. ៥-១៦ ពលសូត្រ |
| | 263 | 9 | អវតំសកសូត្រ ៦ |
| | 264 | 14 | មហាបរិនិព្វានសូត្រ |
| | 265 | 11 | សំយុក្តវត្ថុបិដកសូត្រ ២៦ |
| | 266 | 10 | សុវណ៌ ប្រភាសសូត្រ ២៦ |
| | 267 | 12 | មហាបរិនិព្វានសូត្រ |
| | 269 | 7 | ថេរគាថា អដ្ឋកថា |
| | 270 | 11 | ជាតក ៥៥ បញ្ញាវុធជាតក |
| | 272 | 8 | ឥតិវុត្តក ៣៩-៤០ |
| | 273 | 5 | មហាបរិនិព្វានសូត្រ |
| | 273 | 7 | មហាបរិនិព្វានសូត្រ |
| | 273 | 10 | អ.ន. ៥-១២ |
| | 274 | 3 | បរិនិព្វានសូត្រ |
| | 274 | 15 | សូរំគមសូត្រ |
| 3 | 276 | 12 | ស.ន. ៥៥-២១ ២២ មហានាមសូត្រ |
| | 277 | 13 | អ.ន. ៥-៣២ ចុន្ទីសូត្រ |
| | 278 | 8 | វិមលកិត្តិនិរទេសសូត្រ |
| | 279 | 6 | សូរំគមសូត្រ |
| | 279 | 14 | សុខាវតីព្យូហៈសូត្រ ក្បាលទី ២ |
| | 280 | 9 | ស.ន. ១-៤-៦ |
| | 280 | 13 | អវតំសកសូត្រ ៣៣ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| | 282 | 1 | អវតំសកសូត្រ ២៤ |
| | 283 | 1 | សុវណ៌ប្រភាសសូត្រ ៤ |
| | 283 | 13 | អមិតាយុរធ្យានសូត្រ |
| | 283 | 16 | សុខាវតីព្យូហៈសូត្រ |
| | 284 | 6 | មហាបរិនិព្វានសូត្រ |
| | 285 | 10 | ម.ន. ២-១៦ ចេតោខិលសូត្រ |
| | 286 | 12 | សុខាវតីព្យូហៈសូត្រ ក្បាលទី ២ |
| 4 | 287 | 16 | ធម្មបទ |
| | 298 | 14 | ស.ន. ១-៤-៦ |
| | 299 | 12 | អ.ន. |
| | 299 | 17 | មហាបរិនិព្វានសូត្រ |

## ភាគភាពរាជ័ពុទ្ធសាសនិក

### ចំពូកទី ១

| | | | |
|---|---|---|---|
| 1 | 304 | 1 | ឥតិវុត្តក ១០០, ម.ន. ១-៣ ធម្មទាយាទសូត្រ |
| | 304 | 9 | ឥតិវុត្តក ៩២ |
| | 305 | 8 | វិន័យ មហាវគ្គ ១-៣០ |
| | 306 | 12 | ម.ន. ៤-៣៩ មហាអស្សបុរសូត្រ |
| | 308 | 10 | ម.ន. ៤-៤០ ចូឡអស្សបុរសូត្រ |
| | 310 | 1 | សទ្ធម៌បុណ្ឌរីកសូត្រ ១៩ |
| | 310 | 8 | សទ្ធម៌បុណ្ឌរីកសូត្រ ១៩ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|
| | 310 | 16 | សទ្ធម៌បុណ្ឌរីកសូត្រ១៤ |
| 2 | 312 | 15 | ស.ន. ៥៥-៣៧ មហានាមសូត្រ |
| | 313 | 9 | អ.ន. ៣-៧៥ |
| | 313 | 17 | ស.ន. ៥៥-៣៧ មហានាមសូត្រ |
| | 314 | 6 | ស.ន. ៥៥-៥៤ គិលាយនំសូត្រ |
| | 314 | 11 | អវតំសកសូត្រ ២២ |
| | 316 | 16 | មហាបរិនិព្វានសូត្រ |
| | 321 | 1 | អវតំសកសូត្រ ៧ |
| | 324 | 15 | មហាមាយាសូត្រ |
| | 326 | 8 | អវតំសកសូត្រ ២១ |
| | 327 | 15 | មហាបរិនិព្វានសូត្រ |
| 3 | 330 | 1 | ទ.ន. ៣១ សិង្គាលោវាទសូត្រ |
| | 337 | 16 | អ.ន. ២-៤ សមចិត្តសូត្រ |
| | 338 | 15 | អ.ន. ៣-៣១ |
| | 339 | 5 | ជាតក ៤១៧ កច្ចានិជាតក |
| | 342 | 5 | ទ.ន. ៣១ សិង្គាលោវាទសូត្រ |
| | 343 | 1 | ធម្មបទអដ្ឋកថា ១ |
| | 345 | 4 | តាមអដ្ឋកថាពុទ្ធសាសនាភូមា |
| | 346 | 7 | ស្រីមាលាទេវីសីហនាទសូត្រ |

| វគ្គ | ទំព័រ | បន្ទាត់ | ប្រភពដកស្រង់ |
|---|---|---|---|

**ចំពូកទី ២**

| | | | |
|---|---|---|---|
| 1 | 350 | 1 | មហាបរិនិព្វានសូត្រ |
| | 352 | 11 | អ.ន. ៣-១១៨ សោចេយ្យសូត្រ |
| | 354 | 14 | ស.ន. |
| | 355 | 9 | វិន័យ មហាវគ្គ ១០-១-២ |
| | 356 | 2 | ទ.ន. ១៦ មហាបរិនិព្វានសូត្រ |
| | 357 | 16 | វិន័យ មហាវគ្គ ១០-១-២ |
| 2 | 361 | 16 | ស.ន. |
| | 363 | 6 | សាស្ត្រា ជីអ៊ីផក្ស |
| | 363 | 13 | វិមលកិត្តិនិរទេសសូត្រ |
| | 365 | 10 | មហាបរិនិព្វានសូត្រ |
| | 366 | 12 | សុខាវតីព្យូហៈសូត្រ គម្ពីរតូច |
| | 367 | 3 | សុខាវតីព្យូហៈសូត្រ |
| | 367 | 16 | វិមលកិត្តិនិរទេសសូត្រ |
| 3 | 368 | 11 | ធម្មបទអដ្ឋកថា ១ |
| | 369 | 5 | អ.ន. ៣៤-២ |
| | 370 | 9 | ធម្មបទអដ្ឋកថា ១ |
| | 371 | 11 | អ.ន. ៥-១ |
| | 372 | 1 | មូលសព៌ាស្តិវាទ សង្ឃភេទកពស្តុ ១០ |
| | 373 | 2 | ម.ន . ៩-៨៦ អង្គុលីមាលសូត្រ |
| | 374 | 15 | អ.ន. ២៦ |